បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 13 ខែ 06 ឆ្នាំ 2003

# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០១-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤១២ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ុំ សារិទ្ធិ** ជាទីប្រឹក្សា ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ២៩២០

០៤-១១-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤១៩ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ជូននាយទាហានជាន់ខ្ពស់ចំនួន ០៣ រូបៈ

១- ឧត្តមសេនីយ៍ទោ **មៀន សារិន** មេបញ្ជាការរងកងទ័ពជើងគោក

២- ឧត្តមសេនីយ៍ទោ **អ៊ុំ ម៉ុន្រ្ត** មេបញ្ជាការរងកងទ័ពជើងគោក

៣-ឧត្តមសេនីយ៍ទោ **សុខ សាឯម** មេបញ្ជាការរងកងទ័ពជើងគោក ២៩២១

០៩-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២០ ស្តីពីការតែងតាំង ឯកឧត្តម **ឆឹត រាម** ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាសំរាប់នីតិកាលទី១ ជំនួសឯកឧត្តម **លី អ៊ីមហាន** ដែលទទួលមរណៈភាព ២៩២២

០៩-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២១ ស្តីពីការតែងតាំង លោក **ជ្រាង សុផាន់** ជា ឧកញ៉ា ២៩២៣

០៩-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២២ ស្តីពីការតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **នាម អៀង** ២៩២៤

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២៦ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់**មហាសេនា** ជូន ឯកឧត្តម **ញឹម វណ្ណដា** អនុប្រធាន ទី១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ២៩២៥

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២៧ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូន ឯកឧត្តម **ហ៊ូ សិរីធី** ទីប្រឹក្សាផ្ទាល់ និងជានាយ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៩២៦

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២៨ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម **មុត ខៀវ** នាយករង ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៩២៧

១៤-១១-២០០១ -ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២៩ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម **ថ្លាក់ វណ្ណឌី** នាយករង

ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៩២៨

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤៣០ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម **គឹម ម៉ីនថាន** នាយករង ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៩២៩

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤៣១ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូន ឯកឧត្តម **ហ៊ីង ម៉ុនហៀង** នាយករង ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ២៩៣០

១៤-១១-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១១០១/ ៤២៦ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូន អ្នកឧកញ៉ា **សុខ គង់** អគ្គនាយក ក្រុមហ៊ុន សូគីម៉ិច និងជាប្រធានសភាពាណិជ្ជកម្ម រាជធានីភ្នំពេញ ២៩៣១

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០២-១១-២០០១ - អនុក្រឹត្យលេខ ១១១ អនក្រ .បក ស្តីពីការបង្កើតសាលាជាតិកសិកម្ម កំពង់ចាម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ២៩៣២

០៨-១១-២០០១ - អនុក្រឹត្យលេខ ១១២ អនក្រ .បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ២៩៤៦

០៨-១១-២០០១ - អនុក្រឹត្យលេខ ១១៣ អនក្រ .បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ២៩៤៨

១៣-១១-២០០១ - អនុក្រឹត្យលេខ ១១៤ អនក្រ .បក ស្តីពីការរៀបចំនិងប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ២៩៥០

០៥-១១-២០០១ - អនុក្រឹត្យលេខ ៤៦៣ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៥៧

០៦-១១-២០០១ - អនុក្រឹត្យលេខ ៤៦៤ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៥៩

០៦-១១-២០០១ - អនុក្រឹត្យលេខ ៤៦៥ អនក្រ .តត ស្តីពីការជូនមេដាយការងារ ២៩៦០

០៧-១១-២០០១ - អនុក្រឹត្យលេខ ៤៦៦ អនក្រ .តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៦២

០៨-១១-២០០១ -អនុក្រឹត្យលេខ ៤៦៧ អនក្រ .តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខតំណែងនាយ ទាហាន ២៩៦៣

០៨-១១-២០០១ - អនុក្រឹត្យលេខ ៤៦៨ អនក្រ .តត ស្តីពីការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ ២៩៦៥

១២-១១-២០០១ - អនុក្រឹត្យលេខ ៤៦៩ អនក្រ .តត ស្តីពីការជូនមេដាយការងារ ២៩៦៨

១២-១១-២០០១ - អនុក្រឹត្យលេខ ៤៧០ អនក្រ .តត ស្តីពីការជូនមេដាយសុវត្ថារា ២៩៧២

## គ

១២-១១-២០០១ - អនុក្រឹត្យលេខ ៤៧១ អនក្រ .គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៩៧៤

១២-១១-២០០១ - អនុក្រឹត្យលេខ ៤៧២ អនក្រ .គត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៩៧៨

## ១. សេចក្តីសំរេច

០២-១១-២០០១ - សេចក្តីសំរេចលេខ ៦៦ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២៩៧៩

០៦-១១-២០០១ - សេចក្តីសំរេចលេខ ៦៧ សសរ ស្តីពីការផ្ទេរសិទ្ធិ ២៩៨០

១២-១១-២០០១ - សេចក្តីសំរេចលេខ ៦៨ សសរ ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី ស្តីទី ២៩៨១

១៣-១១-២០០១ - សេចក្តីសំរេចលេខ ៦៩ សសរ ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ២៩៨២

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០២-១១-២០០១ - ប្រកាសលេខ ៣០០ MoC/ M 2001 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរ **Santex Industry (Cambodia) Limited** ២៩៨៣

០២-១១-២០០២ -ប្រកាសលេខ ៣០១ MoC/ M 2001 ស្តីពីស្ថានភាពរោងចក្រកាត់ដេរមួយចំនួន ២៩៨៥

០៨-១១-២០០១ -ប្រកាសលេខ ៣១០ MoC/ M 2001 ស្តីពីស្ថានភាពរោងចក្រ **Intech Footwear Industry Co., Ltd.** ២៩៨៨

## ២. ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

០៥-១១-២០០១ -ប្រកាសលេខ ២៨៦ សកបយ ស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន ២៩៩០

០៥-១១-២០០១ -ប្រកាសលេខ ២៨៧ សកបយ ស្តីពី បែបបទចុះបញ្ជីការ ការផ្សព្វផ្សាយ និងការត្រួតពិនិត្យ ការអនុវត្តន៍អនុសញ្ញារួម ២៩៩៤

០៥-១១-២០០១ -ប្រកាសលេខ ២៨៨ សកបយ ស្តីពីសេចក្តីប្រកាសជូនដំណឹងបើកនិងបិទសហគ្រាស គ្រឹះស្ថាន ២៩៩៧

១៣-១១-២០០១ -ប្រកាសលេខ ៣០០ សកបយ ស្តីពីស្តីពីការឈប់បុណ្យដែលមានប្រាក់ឈ្នួល ៣០០២

## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

១២-១១-២០០១ - សេចក្តីសំរេចលេខ ៣៩១ ធទឧ ស្តីពីការបង្កើតគណៈកម្មាធិការចំរុះ សំរាប់រៀបចំឯកសារ ការអភិវឌ្ឍន៍សកម្មភាព និងទស្សនៈទឹកជាតិ និងបង្កើនការយល់ដឹង ក្នុងការគ្រប់គ្រងធនធានទឹកចំរុះ ៣០០៤

## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

០២-១១-២០០១ សារាចរលេខ ០០១ អយក.សរ ស្តីពីគំរូរចនាសម្ព័ន្ធ និងឈ្មោះសញ្ញាប័ត្រ បច្ចេកទេស និងវិជ្ជាជីវៈ ៣០០៦

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម អ៊ី សារិទ្ធ ជាទីប្រឹក្សារបស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២០៧១ ច.ល

[illegible] ដើម្បីឡាយព្រះហស្តលេខា [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១

[illegible] នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល

[illegible] តាន់

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤១៩

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត/ ១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់សំរេចតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធ ជូននាយទាហានជាន់ខ្ពស់ ចំនួន ០៣ រូប ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងការធ្វើពលីកម្មដើម្បីការពារជាតិ មាតុភូមិ ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយទោ មៀន សរិន មេបញ្ជាការរងកងទ័ពជើងគោក

២-ឧត្តមសេនីយទោ អ៊ុំ បុត្រ មេបញ្ជាការរងកងទ័ពជើងគោក

៣-ឧត្តមសេនីយទោ សុខ សារឹម មេបញ្ជាការរងកងទ័ពជើងគោក

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

លេខ: ៤៣២៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

តាន់

នស/រកត/១១០១/៤២០

# ព្រះរាជក្រឹត្យ

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះមហាក្សត្រ នៃកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៣៩៩ / ០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៨ ៣០ ៣៤ ៥១ ៩០ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែ មីនា ១៩៩៩
- យោងតាមមាត្រា ១១ថ្មី និង ១៥៧ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- យោងតាមសំណើរបស់សម្តេចប្រធានគណបក្សប្រជាជនកម្ពុជា ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១
- យោងតាមសំណើរបស់សម្តេចប្រធានព្រឹទ្ធសភា ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

## ព្រះរាជបញ្ញត្តិ

**មាត្រា១ :** តែងតាំង ឯកឧត្តម និន ទេស ជាសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី១ ជំនួស ឯកឧត្តម ងី គីមហេង ដែលបានទទួលមរណភាព ។

**មាត្រា២ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

លេខ: ២៧៥ ច.ល

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១
អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤២១

យើង

ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក ប្រាង សុផាន់

ជា

ឧកញ៉ា

ព្រះហស្ដលេខា

នរោត្ដម សីហនុ

លេខ: ៤៧៤ ច.ល

[illegible]ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស / រកត / ១១០១/៤២២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ត្រីជូនលោកវរសេនីយ៍ឯក នាម អៀង អត្តលេខ ០០០៣០៧ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ១ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខៈ ៧៩៧ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤២៦

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ជូនឯកឧត្តម **ញឹម វណ្ណដា** អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តនីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ក្នុងឆ្នាំ ២០០០-២០០១ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៧៦ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣៤៧-០១-១១-០០២២

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤២៧

យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនឯកឧត្តម **ហូ សិទ្ធី** ទីប្រឹក្សាផ្ទាល់ និងជានាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តនីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗក្នុងឆ្នាំ ២០០០-២០០១ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ២៧៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣៧-០១-១១-០០២៣

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤២៨

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **មុត ខៀវ** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ក្នុងឆ្នាំ ២០០០-២០០១ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៧៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣៤៧-០១-១១-០០២៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤២៩

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **ច្រាក់ ចណ្ណឌី** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តនីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ក្នុងឆ្នាំ ២០០០-២០០១ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៧៧៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

៣រ៧.០១-១១-០០២៤

**[illegible]**

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣០

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ៥ស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **គីម ប៊ុនថាន** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ក្នុងឆ្នាំ ២០០០-២០០១ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៤៨០ ច.ល

ដើម្បីចម្លងចែកជូន

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

ធ្វើទៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣.ស. ០១-១១-០០២៦

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ជូនឯកឧត្តម **ហ៊ីង ប៊ុនហៀង** នាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តនីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានធ្វើសកម្មភាពជួយសង្គ្រោះប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិ និងគ្រោះមហន្តរាយផ្សេងៗ ក្នុងឆ្នាំ ២០០០-២០០១ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១*

៣រល-០១-១១-០០២៩

លេខ: ៤៨១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

# ព្រះរាជក្រឹត្យ

នស/រកត/១១០១/៤៣២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ព្រះរាជបញ្ញត្តិ

មាត្រា ១ : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ជូនអ្នកឧកញ៉ា ស៊ុខ គង់ អគ្គនាយកក្រុមហ៊ុនសូគីម៉ិច និងជាប្រធានសភាពាណិជ្ជកម្មរាជធានីភ្នំពេញ ដែលមានគុណបំណាច់ខ្ពស់ និងស្នាដៃល្អ ក្នុងការចូលរួមជាមួយរាជរដ្ឋាភិបាល ស្តារអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ព្រះពុទ្ធសាសនា និងទ្រទ្រង់កិច្ចការពារជាតិ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ២៨២ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

ផ្ញើទៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

៣៤៧.០១.១១.០០២៨

...តាន

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ..១១១..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើត សាលាជាតិកសិកម្ម កំពង់ចាម
## ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១/ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៧ ស្តីពី លក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ/បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០០១

សំរេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះរៀបចំឡើង ដើម្បីធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៦៩ អនក្រ/បក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាកសិកម្មកំពង់ចាម ។

សាលាកសិកម្មកំពង់ចាម ត្រូវបានសំរេចឱ្យប្តូរឈ្មោះជា សាលាជាតិកសិកម្មកំពង់ចាម សរសេរកាត់ ស.ជ.ក.ក.ចសំរេចឱ្យទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២.-

ស.ជ.ក.ក.ច ជានីតិបុគ្គល ដែលមានស្វ័យភាពហិរញ្ញវត្ថុ ។

ស.ជ.ក.ក.ច មានអាស័យដ្ឋាន : សាលាជាតិកសិកម្មកំពង់ចាម ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ។

ការផ្លាស់ប្តូរអាស័យដ្ឋាននៅពេលអនាគត ជាសមត្ថកិច្ចរបស់ ស.ជ.ក.ក.ច ។

មាត្រា ៣.-

ស.ជ.ក.ក.ច មានភារកិច្ចដូចតទៅ ÷

- បណ្តុះបណ្តាលអ្នកបច្ចេកទេសកសិកម្មគ្រប់កំរិត ជាអាទិភាពកំរិតសញ្ញាប័ត្រជាន់ខ្ពស់ បច្ចេកទេសកសិកម្ម តាមប្រព័ន្ធ ដែលមានលក្ខណៈថ្មីស្តី និងការអនុវត្តនី បណ្តុះបណ្តាល និងបំប៉នមុខជំនាញវិជ្ជាជីវៈកសិកម្ម តាមសំណូមពរចាំបាច់របស់សង្គម

- សហការជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាលាកសិកម្មព្រែកលៀប សាកលវិទ្យាល័យ វិទ្យាស្ថាននានាក្នុងប្រទេស ក្រៅប្រទេស និងទំនាក់ទំនងសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័ននានា ដើម្បីធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេសកសិកម្ម

- សុំការទទួលស្គាល់កម្មវិធីសិក្សាប្រចាំឆ្នាំពីក្រសួងអប់រំ យុវជន និងកីឡា

- ផ្តល់ និងរួមផ្តល់ជាមួយគ្រឹះស្ថានបណ្តុះបណ្តាលកសិកម្មដទៃទៀត នូវសញ្ញាប័ត្រកំរិតជាតិ

- សិក្សាស្រាវជ្រាវកម្មវិធីសិក្សា ខ្លឹមសារសិក្សា វិធីសាស្ត្របង្រៀន ចងក្រងឯកសារបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម ជាភាសាខ្មែរ និងភាសាបរទេស

- រៀបចំនិងដំណើរការ ការងារប្រឡងជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន ប្រឡងចេញ វាយតម្លៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ និងប្រកបដោយតម្លាភាព



... ⁄5

- កសាងផែនការមូលដ្ឋានសំភារៈសំរាប់ ស.ជ.ក.ក.ច
- កសាងគំរោងផែនការអភិវឌ្ឍន៍ ស.ជ.ក.ក.ច ឱ្យបានសមស្របទៅតាមសភាពការណ៍រីកចំរើនរបស់ប្រទេសជាតិ
- គ្រប់គ្រងមន្ត្រីរាជការ និយោជិត កម្មករ សិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ និងទ្រព្យសម្បត្តិរបស់ ស.ជ.ក.ក.ច ។

## ជំពូកទី ២
## រដ្ឋបាល និងការគ្រប់គ្រង
### ផ្នែកទី ១
### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

ស.ជ.ក.ក.ច ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងទូលំទូលាយដើម្បីចាត់ចែងការងារក្នុងក្របខ័ណ្ឌតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

**មាត្រា ៥.-**

៥.១. ក្រុមប្រឹក្សាភិបាលមានសមាជិក ១១ រូប ដែលមានសមាសភាពដូចតទៅ ÷

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ..........................................ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ..............................................................សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ.....................................................សមាជិក
- តំណាងក្រសួងអប់រំ យុវជន និង កីឡា .....................................................សមាជិក
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ...............................................................សមាជិក
- តំណាងក្រសួងធនធានទឹក និង ឧតុនិយម.................................................សមាជិក
- តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា.........សមាជិក
- តំណាងអភិបាលខេត្តកំពង់ចាម .............................................................សមាជិក
- នាយកសាលាជាតិកសិកម្មកំពង់ចាម.......................................................សមាជិកស្វ័យប្រវត្តិ
- តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្មដែលមានចំណេះដឹង និងបទពិសោធន៍ខ្ពស់...សមាជិក
- តំណាងបុគ្គលិកសាលាជាតិកសិកម្មកំពង់ចាម...........................................សមាជិកស្វ័យប្រវត្តិ

៥.២.ប្រធាន និងសមាជិក នៃក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវតែងតាំងដោយអនុក្រឹត្យ សំរាប់អាណត្តិ ៣ (បី)ឆ្នាំ រៀបចំដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើ របស់ក្រសួង ឬ អាជ្ញាធរដែលខ្លួនតំណាងឱ្យ ។

៥.៣.តំណាងបុគ្គលិក ត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិក ស.ជ.គ.គ.ច ។

**មាត្រា ៦.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីដែលសកម្មធ្លាប់បានបំរើការងារយ៉ាងតិច៥(ប្រាំ) ឆ្នាំ ឬជាឥស្សរជនដែលមានអាយុមិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ អប់រំ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និងពុំដែលធ្លាប់ទទួលទោសព្រហ្មទណ្ឌ កំរិតធ្ងន់ពីតុលាការឡើយ ។

**មាត្រា ៧.-**

៧.១. ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីកោះប្រជុំ និងកំណត់របៀបវារៈ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។

៧.២. ក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យបណ្តុះបណ្តាលកសិកម្ម គ្រប់គ្រងសេដ្ឋកិច្ចកសិកម្ម អភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម ការងារស្រាវជ្រាវកសិកម្ម និង តំណាងអ្នកផ្តល់ជំនួយចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនេះ មានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំ តំរង់ទិសដៅ និងធ្វើការត្រួតពិនិត្យលើដំណើរការរបស់ ស.ជ.គ.គ.ច។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ÷

- ពិនិត្យ និងសំរេចលើគំរោងផែនការអភិវឌ្ឍន៍ ស.ជ.គ.គ.ច ស្របតាមទិសដៅកំណត់ របស់រាជរដ្ឋាភិបាល
- ពិនិត្យ និងសំរេច លើចំណូល និងចំណាយជាប្រចាំ ព្រមទាំងទុនក្នុងថវិកាប្រចាំឆ្នាំរបស់ ស.ជ.គ.គ.ច
- ពិនិត្យ និងសំរេច លើរបាយការណ៍គ្រប់គ្រង និងលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ និងរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅ ដល់អង្គភាពក្រោមឱវាទ
- កំណត់នូវរបបជ្រើសរើស ការតម្លើងឋានន្តរសក្តិ ការផ្តល់លាភការដល់បុគ្គលិក ស.ជ.គ.គ.ច ដោយមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬបទបញ្ជាផ្ទៃក្នុង ដែលអនុវត្តចំពោះភ្នាក់ងារមុខងារសាធារណៈ
- សំរេច លើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសំរាប់ ស.ជ.គ.គ.ច

- សំរេចលើកិច្ចសន្យាស្តីពីលទ្ធកម្ម

- កំណត់បទបញ្ជាផ្ទៃក្នុង ស.ជ.ក.គ.ច

- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកិច្ចលទ្ធផលសំរេចបាន តាមគោលដៅកំណត់ដោយ ស.ជ.ក.គ.ច ហើយកំណត់នូវវិធានការកែតម្រូវដើម្បីអនុវត្ត ។

មាត្រា ៩.-

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល និងប្រាក់បំណាច់របស់នាយក ស.ជ.ក.គ.ច ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

មាត្រា ១០.-

១០.១. ក្រុមប្រឹក្សាភិបាលនៃ ស.ជ.ក.គ.ច ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញរបស់ប្រធាន ឬ តាមសំណើរបស់សមាជិក ចំនួន ២/៣ (ពីរភាគបី)ឡើងទៅ ឬតាមការស្នើសុំពីនាយក ស.ជ.ក.គ.ច ។

ក្នុងករណីប្រធានមានធុរៈ ត្រូវជ្រើសរើសសមាជិកណាម្នាក់ ដែលមានវ័យចំណាស់ជាងគេ ក្នុងចំណោមសមាជិករបស់ក្រុមប្រឹក្សាភិបាលវត្តមាន ដើម្បីដឹកនាំការប្រជុំ ។

ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ១ (មួយ)រូប ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាភិបាល ។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិក នៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃប្រជុំ ។

១០.២.ការប្រជុំរបស់ក្រុមប្រឹក្សាភិបាលអាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមាន ចំនួនលើសពី៥០ (ហាសិប)ភាគរយ នៃសមាជិកទាំងអស់ ។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាងឱ្យមក ប្រជុំជំនួសខ្លួនបានឡើយ ។ បើសិនសម្លេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ១៥ (ដប់ប្រាំ) ថ្ងៃក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈនៃការអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមានមួយ ។ សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល អាចយកជាការបានលុះត្រាតែមានការអនុម័តដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព ។

១០.៣. សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយតំកល់ទុកនៅទីស្នាក់ការ ស.ជ.ក.គ.ច និងត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះ ត្រូវបង្ហាញ

នូវអត្ថន័យ នៃការពិភាក្សាឱ្យបានច្បាស់លាស់ នឹងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងផ្ញើជូនក្រសួងពាក់ព័ន្ធ យ៉ាងយូរ ១០ (ដប់) ថ្ងៃ ក្រោយពេលប្រជុំ ។

១០.៤. ស.ជ.ក.ក.ច ត្រូវផ្ញើជូនទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ ÷

- កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍របស់ ស.ជ.ក.ក.ច
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្តីពីការគ្រប់គ្រង និង គណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥. ឯកសារទាំងនេះត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ។

## ផ្នែកទី ២
## អង្គការប្រតិបត្តិរបស់ សាលាជាតិកសិកម្ម កំពង់ចាម

**មាត្រា ១១.-**

ស.ជ.ក.ក.ច ត្រូវគ្រប់គ្រងដោយនាយកមួយរូប ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ នាយកនេះ មានតួនាទីជានាយកប្រតិបត្តិ ។

**មាត្រា ១២.-**

១២.១.នាយក ស.ជ.ក.ក.ច មានសិទ្ធិពេញលេញដើម្បីគ្រប់គ្រង និងអនុវត្តការងារដែលមានចែងក្នុងច្បាប់ និងអនុក្រឹត្យនេះ លើកលែងតែកិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

នាយកមានភារកិច្ច ÷

- រៀបចំការងារប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការនូវផែនការអភិវឌ្ឍន៍ ដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកាប្រចាំឆ្នាំសំរាប់ ស.ជ.ក.ក.ច ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ សំរេច
- ធ្វើរបាយការណ៍ប្រចាំឆ្នាំរាល់សកម្មភាពត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ឯកសារទាំងនេះជូនក្រុមប្រឹក្សាភិបាលពិនិត្យ សំរេច
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ ស.ជ.ក.ក.ច ក្នុងក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សា -

ភិបាល ព្រមទាំងគោរពតាមវិធាន ស្តីពីការគ្រប់គ្រងបុគ្គលិក

- បំពេញតួនាទីតាមឋានានុក្រម ចំពោះបុគ្គលិកទាំងមូលនៃ ស.ជ.ក.ក.ច

- សំរេចលើការងារលទ្ធកម្ម និងចុះហត្ថលេខាលើអនុសញ្ញាផ្សេងៗ ដែលអនុលោមទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀតស្តីពីបញ្ហានេះ ។

ជារួមគឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលត្រូវបានប្រគល់ឱ្យតាមបទបញ្ជាផ្ទៃក្នុងរបស់ ស.ជ.ក.ក.ច និងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២.នាយក ស.ជ.ក.ក.ច ជាតំណាង ស.ជ.ក.ក.ច ក្នុងការទំនាក់ទំនងជាមួយតតិយជន ។

១២.៣.នាយក ស.ជ.ក.ក.ច ត្រូវស្នើទៅក្រុមប្រឹក្សាភិបាល ដើម្បីក្រុមប្រឹក្សាភិបាលនេះស្នើសុំតែងតាំងនាយករង មួយរូប ឬ ច្រើនរូប សំរាប់ជួយការងាររបស់ខ្លួនតាមការចាំបាច់ ។

## ផ្នែកទី ៣

## បុគ្គលិករបស់ សាលាជាតិកសិកម្ម កំពង់ចាម

**មាត្រា ១៣.-**

១៣.១..បុគ្គលិកអចិន្ត្រៃយ៍របស់ ស.ជ.ក.ក.ច រួមមានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬជ្រើសរើសតាមសំណើរបស់នាយកនៃ ស.ជ.ក.ក.ច ។ មន្ត្រីទាំងនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កំរៃផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

១៣.២. ស.ជ.ក.ក.ច អាចជ្រើសរើសភ្នាក់ងារជាប់កិច្ចសន្យាជំនួយការ និងបុគ្គលិកអណ្តែត ភ្នាក់ងារទាំងនេះត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ ។

១៣.៣.បុគ្គលិក ស.ជ.ក.ក.ច ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជា ស្តីពីបុគ្គលិកសំរេចដោយក្រុម-ប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កំរៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទូទាត់ផងដែលមានចែងនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

## ផ្នែកទី ៤

## ធនធានសម្បត្តិរបស់ សាលាជាតិកសិកម្ម កំពង់ចាម

មាត្រា ១៤.-

១៤.១. ស.ជ.ក.ក.ច ទទួលដើមទុនដំបូងពីរដ្ឋ នូវអចលនៈវត្ថុដូចតទៅ ÷

- ដីជាទីតាំងនៃ ស.ជ.ក.ក.ច មានផ្ទៃដី ២៣.៥៧១ម៉ែ ស្ថិតនៅភូមិទី ៦ ឃុំវាលវង់ ស្រុកកំពង់ចាម ខេត្តកំពង់ចាម ស្ថិតលើផ្ទៃដី នៃអតីតសាលាកសិកម្មកំពង់ចាម ។

- អាគារសិក្សា អន្តេវាសិកដ្ឋាន ស្ថានីយ៍អនុវត្ត អាគារមន្ទីរពិសោធន៍ អាគារសមាសិក្សា ។

១៤.២.ក្រៅពីអចលនៈទ្រព្យខាងលើ ស.ជ.ក.ក.ច ត្រូវបានទទួលនូវចលនៈទ្រព្យនិងអចលនៈទ្រព្យផ្សេងៗ ដែលកំពុងប្រើប្រាស់ពេលបច្ចុប្បន្ន ។

១៤.៣.អចលនៈទ្រព្យ និងចលនៈទ្រព្យទាំងអស់របស់ស.ជ.ក.ក.ចនឹងមានចែងលំអិតក្នុងបញ្ជីសារពើភ័ណ្ឌ។

១៤.៤. ស.ជ.ក.ក.ច អាចទិញ លក់ចលនៈទ្រព្យ និងទិញអចលនៈទ្រព្យចាំបាច់សំរាប់ដំណើរការរបស់ខ្លួន ។

## ជំពូកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ របស់សាលាជាតិកសិកម្ម កំពង់ចាម

មាត្រា ១៥.-

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ ស.ជ.ក.ក.ច ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃគណនេយ្យសាធារណៈ ដូចមានចែងនៅក្នុងមាត្រា១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។

មាត្រា ១៦.-

១៦.១. នាយក ស.ជ.ក.ក.ច ជាអាណាប័កដើមខ្សែ ហើយត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ប្រាក់ចំណូល

- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២. អាណាប័កដើមខ្សែអាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបាន ដោយមានការព្រមព្រៀងពីភ្នាក់ងារគណនេយ្យ ។

មាត្រា ១៧.-

១៧.១. ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់ ស.ជ.ក.ក.ច ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវតែងតាំង

ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវសច្ចាប្រណិធានមុនចូលកាន់ការងារ ភ្នាក់ងារគណនេយ្យនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសម្លេងឆ្នោតឡើយ ។

១៧.២.ភ្នាក់ងារគណនេយ្យមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ ស.ជ.គ.ក.ច
- រក្សាទុកលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

១៧.៣.ភ្នាក់ងារគណនេយ្យអាចផ្ទេរសិទ្ធិខ្លះទៅឱ្យអាជ្ញានុករីរបស់ខ្លួន ។

**មាត្រា ១៨.-**

១៨.១. ប្រភពធនធានរបស់ ស.ជ.គ.ក.ច រួមមាន ÷

ធនធានដំបូង ដែលរដ្ឋផ្ដល់ជូន ស.ជ.គ.ក.ច នៅពេលផ្ដើមបង្កើតដំបូង

- ឧបត្ថម្ភធនសំរាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និងអច្ច័យទានដែល ស.ជ.គ.ក.ច បានទទួល
- ប្រាក់ខ្ចីបុលដោយ ស.ជ.គ.ក.ច ផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ ស.ជ.គ.ក.ច
- ផលនៃការងារ និងកំរៃ នៃការផ្ដល់សេវាផ្សេងៗ ដោយ ស.ជ.គ.ក.ច
- កំរៃ នៃទ្រព្យសម្បត្តិរបស់ ស.ជ.គ.ក.ច និងចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការ អនុញ្ញាតពីរាជរដ្ឋាភិបាល
- កំរៃ នៃទ្រព្យសម្បត្តិ ដែលបានប្រគល់ឱ្យ ស.ជ.គ.ក.ច ។

១៨.២.ចំណូលនិងចំណាយជាប្រចាំ ព្រមទាំងមូលធនរបស់ ស.ជ.គ.ក.ច ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំ របស់ ស.ជ.គ.ក.ច ។ ក្រុមប្រឹក្សាភិបាលរបស់ ស.ជ.គ.ក.ច ត្រូវចែងអំពីបែបបទ នៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ។ សេចក្ដីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទំរង់បែបបទ នៃការរៀបចំ ការចាត់ចែង និងអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៨.៣.ថវិកា ត្រូវរៀបចំដោយនាយកប៉ែកដើមឡៃ នៃ ស.ជ.គ.ក.ច ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសំរេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹងរវាងចំណូល និងចំណាយ ។



15

មាត្រា ១៩.-

១៩.១. ការងារគណនេយ្យ របស់ ស.ជ.គ.គ.ច រួមមាន ÷

- គណនេយ្យទូទៅ ត្រូវកាន់ការជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ ប្រតិបត្តិការ ដែលអនុវត្តជាមួយតតិយជន

- គណនេយ្យអសង្ហារិម រូបធាតុ និងគណនេយ្យតម្លៃ

- គណនេយ្យវិភាគ ប្រសិនបើវាការចាំបាច់

គណនេយ្យរបស់ ស.ជ.គ.គ.ច ត្រូវ ÷

១- ស្របតាមវិធានដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- គោរពតាមប្លង់គណនេយ្យរបស់ ស.ជ.គ.គ.ច ដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។

ប្លង់គណនេយ្យនេះ ត្រូវទទួលការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.២. គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ស.ជ.គ.គ.ច ត្រូវរៀបចំដោយភ្នាក់ងារគណនេយ្យ និងអាណាប័ក ដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសំរេចលើឯកសារទាំងនោះយ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

មាត្រា ២០.-

មូលនិធិរបស់ ស.ជ.គ.គ.ច គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយនៅរតនាគារ ជាចាំបាច់ លើកលែង មានបដិប្បញ្ញត្តិដែលត្រូវមានការយល់ព្រមតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃ សាលាជាតិកសិកម្ម កំពង់ចាម

មាត្រា ២១.-

លើកលែងតែមានបដិប្បញ្ញត្តិ ដែលចែងដោយច្បាប់ ស.ជ.គ.គ.ច ត្រូវស្ថិតនៅក្រោមនីតិរូប ចំពោះរបបសារពើពន្ធដូចដែលត្រូវបានអនុវត្តលើអង្គភាពនានា របស់រដ្ឋ ។

## ផ្នែកទី ៧

## លទ្ធកម្មរបស់ សាលាជាតិកសិកម្ម កំពង់ចាម

មាត្រា ២២.-

ការសំរេចការអនុវត្តន៍ និងការត្រួតពិនិត្យលើលទ្ធកម្មរបស់ ស.ជ.គ.គ.ច ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យលេខ ៦០ អនក្រ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីលទ្ធកម្មសាធារណៈ និងបទបញ្ជាដទៃទៀតពាក់ព័ន្ធនឹងបទបញ្ជានេះ ។

# ជំពូកទី ៣

# អាណាព្យាបាល

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣.-**

២៣.១.ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក ស.ជ.ក.ក.ខ ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគំរោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល១ (មួយ) ខែ ចាប់ពីថ្ងៃដែលបានទទួលឯកសារ ត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមានពេល ២(ពីរ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារដែលបញ្ជូនដោយនាយក ស.ជ.ក.ក.ខ ដើម្បីសំរេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២.លិខិតផ្តល់ការយល់ព្រមចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង ត្រូវផ្ញើជូនទៅនាយក ស.ជ.ក.ក.ខ ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយក ស.ជ.ក.ក.ខ ត្រូវបញ្ជូនពត៌មាននេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកាប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកានេះ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយ សំរាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍នៃ ស.ជ.ក.ក.ខ និងថវិកាចំណាយជាមូលធន មិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

ថវិកាចំណាយជាប្រចាំអាចដាក់ឱ្យអនុវត្តត្រឹមលំនាំបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះ នៅពេលដែលមានការជំទាស់ពីប្រធានស្ថាប័ន ឬអាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤.-**

២៤.១. រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចមានយោបល់ជំទាស់លើឯកសារ ដែលបានត្រូវបញ្ជូនមកខ្លួនដូចមានចែងក្នុងមាត្រា ២៣ ខាងលើមាន ÷ កំណត់ហេតុនៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍

ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានរយៈពេល ១ (មួយ) ខែ សំរាប់លើកឡើងនូវការជំទាស់ទាំងអស់នោះ ។

២៤.២.នាយក ស.ជ.គ.គ.ច ត្រូវជូនពត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរិះរកមធ្យោបាយសំរាប់ដោះស្រាយ ការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិបាលសំរេច ពុំយកជាបានការនូវការជំទាស់ទាំងនោះ សេចក្តីសំរេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២៥.-**

២៥.១ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចលុប ឬផ្អាកទុកនូវសេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ ស.ជ.គ.គ.ច ក្នុងករណីដែលសេចក្តីសំរេចនោះ ÷

- ផ្ទុយនឹងគោលដៅរបស់ ស.ជ.គ.គ.ច
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ ។

២៥.២.ការលុបចោល ឬការផ្អាកទុកនេះ ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬតាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬការផ្អាកទុកនូវសេចក្តីសំរេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយក ស.ជ.គ.គ.ច ហើយនាយកត្រូវជូនពត៌មាន បន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចចាត់ឱ្យធ្វើអធិការកិច្ច ឬការត្រួតពិនិត្យ ការងារក្នុង ស.ជ.គ.គ.ច ក្នុងករណីដែលយល់ថាជាការចាំបាច់ស្របតាមលក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។

## ផ្នែកទី ២

## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា ២៧.-**

២៧.១.ក្នុងរយៈពេល ១៥(ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល នាយក ស.ជ.គ.គ.ច ត្រូវផ្ញើរបាយការណ៍ ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានរយៈពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានពេល ២(ពីរ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមក ដោយនាយក ស.ជ.គ.គ.ឧ ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

២៧.២.លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយក ស.ជ.គ.គ.ឧ ដោយមានចម្លងជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។ នាយកនៃ ស.ជ.គ.គ.ឧ ត្រូវជូនពត៌មាននេះ ដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេលដូចបានកំណត់ខាងលើ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានយោបល់ជំទាស់លើរបាយការណ៍ ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុតដើម្បីរករកមធ្យោបាយដោះស្រាយការជំទាស់ទាំងនោះ ។

របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសំរេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

## មាត្រា ២៨.-

សេចក្តីសំរេចដូចរៀបរាប់របស់ក្រុមប្រឹក្សាភិបាល ឬនាយក ស.ជ.គ.គ.ឧ ខាងក្រោមនេះ ត្រូវដាក់សុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួមមាន ÷

- សេចក្តីសំរេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនៈទ្រព្យ
- សេចក្តីសំរេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។
- សេចក្តីសំរេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសំរាប់ការធានា ឬលិខិតស្រដៀងគ្នានេះ ។

## មាត្រា ២៩.-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូបប្រចាំ ស.ជ.គ.គ.ឧ ។ មន្ត្រីនេះមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និង ជាក្រោយលើ ស.ជ.គ.គ.ឧ ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកាតាមក្រសួងអង្គភាពមូលដ្ឋាន តាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣០.-**

៣០.១.ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ ស.ជ.គ.ក.ច ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២.ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ភ្នាក់ងារគណនេយ្យកណ្តាលនៃ ធនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣០.៣.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ ធ្វើអធិការកិច្ច ឬ ត្រួតពិនិត្យលើ ស.ជ.គ.ក.ច នៅពេលដែលយល់ថាចាំបាច់ស្របតាមលក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

អនុក្រឹត្យលេខ ៦៩ អនក្រ/បក ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតសាលាកសិកម្ម កំពង់ចាម និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួង ព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៣២
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៦ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពីការផ្ដល់ឥណទានថវិកាបន្ថែមលើឥណទានថវិកា របស់ទីស្ដីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្ដីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ដោយអនុលោមទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ ០១.នស៩៣ . ចុះថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ១៩៩៣ ត្រូវបានអនុញ្ញាតិផ្តល់បន្ថែមឥណទានថវិកា ចំនួន ១៧.៥០០ លានរៀល ( ដប់ប្រាំពីរពាន់ ប្រាំរយលានរៀលគត់ ) ទៅលើសៀវភៅថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ ត្រូវបានផ្តល់បន្ថែមទៅ ជំពូក ១១ ( ចំណាយលើការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី ដែលខ្វះក្នុង ឆ្នាំ ២០០១ ។

**មាត្រា៣:** ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា៤:** ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

**មាត្រា៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមលើឥណទានថវិកា របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

ប្រការ១: ដោយយោងទៅតាមមាត្រា ៤៦ នៃច្បាប់ស្តីពី **ប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយ** ប្រើដោយព្រះរាជក្រម លេខ ០១.នស៩៣ . ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ **១៩៩៣ ត្រូវបានអនុញ្ញាតិផ្តល់** បន្ថែមឥណទានថវិកា ចំនួន ២៩.០០០ លានរៀល ( ម្ភៃប្រាំបួនពាន់លានរៀលគត់ ) **ទៅលើសៀវភៅថវិកា** របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

ប្រការ២: ឥណទានបន្ថែមដូចបានកំណត់ក្នុងមាត្រា ១ ខាងលើ **ត្រូវបានផ្តល់បន្ថែមទៅ ជំពូក ១១** ( ចំណាយលើការគាំទ្រ ផ្តល់ សំភារៈ និង ការផ្គត់ផ្គង់ ) **របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ទូទាត់ចំណាយគ្រោះទឹកជំនន់** និង គ្រោះរាំងស្ងួត ក្នុងឆ្នាំ ២០០០ ។

ប្រការ៣: ការបែងចែកឥណទានបន្ថែមផ្ទៃក្នុងជំពូក តាមប្រការ **កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ** ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ប្រការ៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុង**ច្បាប់ហិរញ្ញវត្ថុ** នាពេលខាងមុខ ការបើកចំណាយពិសេសនេះត្រូវបានចប់សព្វគ្រប់ ។

ប្រការ៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- កាលប្បវត្តិ . ឯកសារ

បានយកសេចក្តីគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## នៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៦ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

# ស ម្រេ ច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់បេសកកម្ម មុខងារ ភារកិច្ច និងការរៀបចំអគ្គលេខាធិការដ្ឋាន របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## ជំពូកទី ២

## បេសកកម្ម រចនាសម្ព័ន្ធ មុខងារ និងភារកិច្ច

**មាត្រា ២.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានបេសកកម្មផ្តួចផ្តើម ជំរុញ ដាក់ឱ្យដំណើរការ និងតាមដានការអនុវត្តគោលនយោបាយ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ស្របតាមទិសដៅរបស់ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ជាពិសេសពង្រឹងប្រព័ន្ធតុលាការជាតិ ។

**មាត្រា ៣.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ ។

**មាត្រា ៤.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានមុខងារ និងភារកិច្ចដូចតទៅ ÷

១. ផ្តួចផ្តើម និងលើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវគម្រោងផែនការ កម្មវិធី កម្មវិធីការងារ និងយុទ្ធសាស្ត្រ សម្រាប់ធ្វើឱ្យសម្រេចគោលដៅទាំងឡាយនៃកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

២. អនុវត្តសេចក្តីណែនាំ ដែលទទួលបានពីឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ក្នុងការដាក់ឱ្យដំណើរការយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៣. ចេញសេចក្តីសម្រេច និងសេចក្តីណែនាំចាំបាច់ដល់គ្រប់ក្រសួង ស្ថាប័ន ក្នុងការដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ក្នុងព្រំដែនសមត្ថកិច្ចរបស់ខ្លួន ។

៤. សម្របសម្រួលបណ្តាសកម្មភាពរបស់ក្រសួងនានា ដែលទាក់ទងទៅនឹងកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៥. តាមដានអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ នៅតាមក្រសួងនានានិងរាយការណ៍ពីលទ្ធផលទទួលបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ។

៦. លើកសំណើជូនឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ នូវវិធានការចាំបាច់ទាំងឡាយក្នុងការដាក់ឱ្យដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៧. ទំនាក់ទំនង សម្របសម្រួល យកចិត្តទុកដាក់ ដល់ការកេណ្ឌធនធានផ្ទាល់របស់រដ្ឋ និងជំនួយអន្តរជាតិចាំបាច់ សម្រាប់យកមកប្រើប្រាស់ ក្នុងការដាក់ឱ្យដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

៨. ផ្តល់ជូនក្រសួង ស្ថាប័នរដ្ឋក្នុងព្រំដែនសមត្ថភាពរបស់ខ្លួន នូវបង្អែកបច្ចេកទេសដែលមានអត្ថប្រយោជន៍ ដល់ក្រសួងទាំងអស់នោះ ពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## មាត្រា ៥.-

ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានភារកិច្ចដូចតទៅ ៖

- ទទួលខុសត្រូវរួម ក្នុងការដាក់ឱ្យអនុវត្តនយោបាយ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- កំណត់របៀបវារៈនៃការប្រជុំនានា របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- ដឹកនាំការពិភាក្សា និងចេញសេចក្តីសម្រេចនានា
- លើកសំណើ របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជូនក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ ឬរាជរដ្ឋាភិបាលនូវគម្រោងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

## មាត្រា ៦.-

ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌មានសិទ្ធិ ៖

- លើកសំណើតែងតាំង តាមករណីចាំបាច់ នូវអ្នកជំនាញការជាតិ អន្តរជាតិ និងឥស្សរជន ឬមន្ត្រីជាន់ខ្ពស់ដែលមានជំនាញក្នុងវិស័យនីតិកម្ម រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច ឬអភិបាលកិច្ចជាទីប្រឹក្សា ដើម្បីសិក្សាវិភាគធ្វើទស្សនទាន ឬធ្វើផែនការកម្មលើវិស័យកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

- អញ្ជើញសមាជិករាជរដ្ឋាភិបាល ឬឥស្សរជន ដែលមានគុណសម្បត្តិមកចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

- អាចចុះហត្ថលេខាទ្វេភាគី ឬពហុភាគីលើគ្រប់កិច្ចសន្យា ឬអត្ថបទគតិយុត្តដែលទាក់ទងទៅនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌បាន

- គ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

## ជំពូកទី ៣

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានដឹកនាំ និងគ្រប់គ្រង ដោយអគ្គលេខាធិការមួយរូប ។ អគ្គលេខាធិការមានអគ្គលេខាធិការរង និងមន្ត្រីជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានអគ្គលេខាធិការរងម្នាក់ទទួលបន្ទុកការងារអចិន្ត្រៃយ៍ ។

អគ្គលេខាធិការរង ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់អគ្គលេខាធិការ ដោយមានមតិយល់ព្រមពីប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ៨.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានបេសកកម្មដាក់ឱ្យដំណើរការកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។ ក្នុងបេសកកម្មនេះ អគ្គលេខាធិការ មានភារកិច្ចជាអាទិ៍ សិក្សា និងលើកសំណើជាក់ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ នូវគម្រោង កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ សម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ព្រមទាំងរៀបចំធ្វើរបាយការណ៍ ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ អំពីលទ្ធភាពនៃការអនុវត្តគម្រោងទាំងនោះ ។

ក្នុងតួនាទីនេះ អគ្គលេខាធិការដ្ឋានមានភារកិច្ចតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោងកំណែទម្រង់យុត្តិធម៌ ព្រមទាំងវាយតម្លៃលទ្ធផលដែលសម្រេចបាន ។

**មាត្រា ៩.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានត្រាផ្ទាល់របស់ខ្លួន ។

**មាត្រា ១០.-**

អគ្គលេខាធិការមានសិទ្ធិលើកសំណើជូន ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីពិនិត្យ និងសម្រេចតែងតាំង ឬដកចេញពីតំណែង នូវមន្ត្រីបុគ្គលិករបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ។

**មាត្រា ១១.-**

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានរចនាសម្ព័ន្ធដូចតទៅ ៖

១. ផ្នែករដ្ឋបាល និងផ្គត់ផ្គង់

២. ផ្នែកច្បាប់

៣. ផ្នែកតុលាការ

៤. ផ្នែកទំនាក់ទំនងនិងសម្របសម្រួល

## មាត្រា ១២.- ផ្នែកច្បាប់

ផ្នែកច្បាប់មានភារកិច្ចដូចតទៅ ៖

- តាមដានការអនុវត្តច្បាប់
- ជំរុញការធ្វើវិសោធនកម្ម និងការកសាងច្បាប់
- ចូលរួមផ្តល់មតិចំពោះសេចក្តីព្រាង និងសេចក្តីស្នើច្បាប់
- រាយការណ៍ និងលើកស្នើយោបល់ការងារខាងលើជូនអគ្គលេខាធិការ
- បំពេញរាល់ការងារដែលអគ្គលេខាធិការ ប្រគល់ឱ្យ ។

## មាត្រា ១៣.- ផ្នែកតុលាការ

ផ្នែកតុលាការមានភារកិច្ចដូចតទៅ ៖

- រៀបចំផែនការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- រៀបចំកម្មវិធី ចូលរួមពិនិត្យតាមដានការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធតុលាការ
- លើកសំណើព្រមទាំងរាយការណ៍ជូនក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- បំពេញរាល់ការងារដែលអគ្គលេខាធិការ ប្រគល់ឱ្យ ។

## មាត្រា ១៤.-ផ្នែករដ្ឋបាល និងផ្គត់ផ្គង់

ផ្នែករដ្ឋបាល និងផ្គត់ផ្គង់ មានមុខងារ និងភារកិច្ចដូចតទៅ ៖

- សម្របសម្រួលផ្នែករដ្ឋបាល នូវរាល់សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗ របស់អគ្គលេខាធិការដ្ឋាន
- ធានាប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន
- សរុប និងធ្វើរបាយការណ៍អំពីការងាររួម និងសកម្មភាពផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន
- ផ្តល់ការគាំទ្រផ្នែកភស្តុភារចាំបាច់ដល់អគ្គលេខាធិការដ្ឋាន
- លើក និងអនុវត្តគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- ប្រមូលផ្តុំចំណូល និងចំណាយរបស់អគ្គលេខាធិការដ្ឋាន
- តាមដាន និងលើកការអនុវត្តថវិកានិងការគ្រប់គ្រងគណនី របស់អគ្គលេខាធិការដ្ឋាន
- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយឱ្យបានសមស្រប
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំ និងសម្រួលកិច្ចប្រជុំ និងការពិភាក្សារបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល
- កសាង និងដាក់ជូន នូវរបាយការណ៍ចំណាយប្រចាំត្រីមាស
- រាយការណ៍ និងលើកសំណើយោបល់ពីការងារខាងលើជូនអគ្គលេខាធិការ
- រក្សាសេវានៃបណ្ណសារ និងឯកសារ ។

**មាត្រា ១៥.- ផ្នែកទំនាក់ទំនង និងសម្របសម្រួល**

ផ្នែកទំនាក់ទំនងនិងសម្របសម្រួល មានមុខងារនិងភារកិច្ចដូចតទៅ ÷

- ប្រមូលទិន្នន័យ និងទំនាក់ទំនងជាមួយស្ថាប័ននានា ដែលមានការពាក់ព័ន្ធនឹងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- សម្របសម្រួលការអនុវត្តកម្មវិធីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ជាមួយប្រទេសផ្តល់ជំនួយ
- កេណ្ឌធនធាននិងជំនួយជាតិ និងអន្តរជាតិសម្រាប់បម្រើការក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌
- បំពេញរាល់ការងារដែលអគ្គលេខាធិការប្រគល់ឱ្យ ។

**មាត្រា ១៦.-**

អគ្គលេខាធិការដ្ឋាន ប្រើប្រាស់បុគ្គលិកនៃមុខងារសាធារណៈ ឬអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាបាន ។ លក្ខខ័ណ្ឌនៃលក្ខការរបស់ភ្នាក់ងារជាប់កិច្ចសន្យា និងប្រាក់បំណាច់ពិសេសសម្រាប់បើកជូនភ្នាក់ងារនៃមុខងារសាធារណៈ ត្រូវកំណត់ដោយសេចក្តីសម្រេច របស់ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ តាមសំណើរបស់អគ្គលេខាធិការ ។

**មាត្រា ១៧.-**

សមាជិក និងបុគ្គលិកទាំងអស់របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ អាចទទួលបាននូវប្រាក់បំណាច់ផ្សេងៗ ដែលបានផ្ទាល់ពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិនានា។

## ជំពូកទី ៣
## ប្រភពធនធាន

**មាត្រា ១៨.-**

ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ មានខ្ទង់ថវិកា ដោយឡែកនៅក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១៩.-**

ធនធាន និងថវិការបស់ក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានផ្គត់ផ្គង់ដោយ ÷

- វិភាគទាននៃថវិកាជាតិ
- ហិរញ្ញប្បទានបានមកពីប្រទេស ឬអង្គការផ្តល់ជំនួយអន្តរជាតិ ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ________

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ២០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីចុះហត្ថលេខា "
ប្រធានក្រុមប្រឹក្សាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

ឌិត មុន្ទី

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១
- ខុទ្ទកាល័យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

## សំរេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាងរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន ចំនួន ០១ រូប ដែលបានផ្តល់ជំនួយឥតសំណង ១៣៥.៨៦២ ដុល្លា និងតំណាងអង្គការទស្សនៈពិភពលោក-កម្ពុជា ចំនួន ០២ រូប ផ្តល់ជំនួយ ៣២៤.១៧០ ដុល្លា ដើម្បីជួយដល់ខេត្តកំពង់ស្ពឺលើការកសាងវិស័យអប់រំ កសិកម្ម និងស្ថាបហេដ្ឋារចនាសម្ព័ន្ធនានា ដូចមានរាយនាមខាងក្រោម ÷

១-លោក **ហ្គោតារ៉ូ អូហ្គាវ៉ា** ( GOTARO OGAWA ) ឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ។

២-លោក **ជូស្ទីន បាយវ័ថ** ( JUSTIN BYWORTH ) នាយកអង្គការទស្សនៈពិភពលោក-កម្ពុជា

៣-លោក **តាតស៊ូហ៊ីរ៉ូ មីនេណូ** ( TATSUHIRO MINENO ) នាយកការិយាល័យប្រតិបត្តិ
ប្រចាំខេត្តកំពង់ស្ពឺ នៃអង្គការទស្សនៈពិភពលោក-កម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តន៍អនុក្រឹត្យនេះ
អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ....០៥.... ខែវិច្ឆិកា.. ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**<u>កន្លែងទទួល</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ០៤ រូប ដែលបានបរិច្ចាគថវិកាដើម្បីជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ស្ថិតនៅក្នុងវត្តសុវណ្ណតេជោ ស្រុកល្វាឯម ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-លោក | **បាន ហ៊ីម** | នៅរាជធានីភ្នំពេញ | ថវិកា | ១២.០០០ USD |
| ២-លោកយាយ | **សុខ រស់** | នៅរាជធានីភ្នំពេញ | ថវិកា | ១០.២៥០ USD |
| ៣-លោកវរសេនីយត្រី | **ឌួប សារ៉េត** | | ថវិកា | ១០.០០០ USD |
| ៤-អ្នកស្រីវរសេនីយត្រី | **មាស សារ៉ា** | | ថវិកា | ១០.០០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។៤

រាជធានីភ្នំពេញ.ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨២៥...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច

## សំរេច

**មាត្រា ១:** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនថ្នាក់ដឹកនាំ និង ក្រុមអធិការកិច្ច នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ដែលមានស្នាដៃល្អក្នុងការធ្វើអធិការកិច្ច ទប់ស្កាត់នូវការចំណាយថវិការដ្ឋមិនសមស្រប ដូចមានរាយនាមខាងក្រោមនេះ ÷

១. ឯកឧត្តម **ឃុន ហាំង** រដ្ឋមន្ត្រី

២. ឯកឧត្តម **ខាយ ឃុនហេង** រដ្ឋលេខាធិការទទួលបន្ទុកអធិការកិច្ច

៣. ឯកឧត្តម **ហ៊ុង ថែម** រដ្ឋលេខាធិការទទួលបន្ទុកទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា

៤. ឯកឧត្តម **ខឹម ជាសោភ័ណ** អគ្គនាយកអធិការកិច្ច

៥. លោក **ជ្រុក ចាន់ណារិទ្ធ** ប្រធាននាយកដ្ឋានទំនាក់ទំនងអធិការកិច្ចតាមបណ្តាស្ថាប័ន

៦. លោក **ប៊ុន លី** មន្ត្រីអធិការកិច្ច

៧. លោក **អៀ វ៉ាន់រ៉ា** មន្ត្រីអធិការកិច្ច

៨. លោក **សេរី ម៉ារណុប** មន្ត្រីអធិការកិច្ច

៩. លោក **លី ដារុទ្ធី** មន្ត្រីអធិការកិច្ច

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ១ និង មាត្រា២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៤១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តព្រៃវែង

**ស ម្រ េ ច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ថ្វាង សុផាន់** និងលោកស្រី **ហ៊ូ ណារី** **អគ្គនាយកក្រុមហ៊ុន ថ្វាង សុផាន់ ពាណិជ្ជ** ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនយ៉ាងច្រើន ដើម្បីរួមចំណែកអភិវឌ្ឍន៍ និង ស្តារហេដ្ឋារចនាសម្ព័ន្ធ ស្ថិតនៅក្នុងស្រុកបី គឺស្រុកកំពង់លាវ ស្រុកកំចាយមារ និង ស្រុកព្រៃវែង ខេត្តព្រៃវែង សរុបទឹកប្រាក់ចំនួន ១៧៧.៣០៩ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ អនក្រ.តក

# អនុក្រឹត្យ

## ស្ដីពីការតែងតាំងផ្លាស់ប្ដូរមុខតំណែងនាយទាហាន

៣ ៣

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត / ០៧០១ / ២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## ស ំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងផ្លាស់ប្ដូរមុខតំណែងនាយទាហាន នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម÷

១- ឧត្តមសេនីយ៍ត្រី នួន ប៉ាក់ អត្តលេខ ០០០៣៨៦ មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ១ បច្ចុប្បន្នជា មេបញ្ជាការរងយោធភូមិភាគទី ១ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

២- លោកវរសេនីយ៍ឯក នាម អៀង អត្តលេខ ០០០៣០៧ នាយសេនាធិការរងយោធភូមិភាគទី ៣ បច្ចុប្បន្នជា មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគទី ១ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១២៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងរដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

********

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ. បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់នៃការងារ

## សំរេច

**មាត្រា១ . -**

តែងតាំងឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជារដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ (GMS) ។

**មាត្រា២ . -**

តែងតាំងឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអ្នកសំរបសំរួលជាតិនៃកម្មវិធីមហាអនុតំបន់មេគង្គ (GMS) និង ជាប្រធាននៃលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ (GMS) ។

លេខាធិការដ្ឋានជាតិទទួលបន្ទុកមហាអនុតំបន់មេគង្គ (GMS) ត្រូវមានទីស្នាក់ការនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៣ . -**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ (GMS) មានភារកិច្ចដូចតទៅ÷

ក. ទទួលខុសត្រូវក្នុងការសំរបសំរួល និង ដឹកនាំការងារសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីមហាអនុតំបន់មេគង្គ ជាមួយនឹងប្រទេសជាសមាជិកដទៃទៀត និង ជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងដៃគូដទៃទៀតដែលមានការពាក់ព័ន្ធ។

ខ. ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីមហាអនុតំបន់មេគង្គ (GMS) ។

គ. ត្រួតពិនិត្យ តាមដាន និង បូកសរុបការអនុវត្តន៍គំរោងសហប្រតិបត្តិការនានា នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីមហាអនុតំបន់មេគង្គ ។

ឃ. រាយការណ៍ជាប្រចាំ អំពីការងាររបស់ខ្លួន និង អំពីលទ្ធផលនៃកិច្ចប្រជុំនានា ពាក់ព័ន្ធនឹងកម្មវិធីមហាអនុតំបន់មេគង្គ ជូននាយករដ្ឋមន្ត្រី- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជ្រាប និង ផ្តល់ការណែនាំ ។

**មាត្រា ៤ . -**

អ្នកសំរបសំរួលជាតិនៃកម្មវិធីមហាអនុតំបន់មេគង្គ (GMS) និង ជាប្រធានលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ (GMS) មានភារកិច្ច ÷

ក. ដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់មហាអនុតំបន់មេគង្គ ។

ខ. ដឹកនាំលេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ ដែលជាស្ថាប័ន «ច្រកចេញចូលតែមួយ» សំរាប់ការងារសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ ដើម្បីជួយដល់រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ ក្នុងការបំពេញភារកិច្ចដូចមានចែងខាងលើ ។

**មាត្រា ៥ . -**

រដ្ឋមន្ត្រីទទួលបន្ទុកកម្មវិធីមហាអនុតំបន់មេគង្គ អ្នកសំរបសំរួលជាតិនៃកម្មវិធីមហាអនុតំបន់មេគង្គ និង លេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ មានសិទ្ធិប្រើប្រាស់ត្រា និង ថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៦ . -**

គ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើតអង្គភាពមហាអនុតំបន់មេគង្គ (GMS Unit) ដើម្បីទទួលបន្ទុកកិច្ចការសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌកម្មវិធីមហាអនុតំបន់មេគង្គ តាមសមត្ថកិច្ចរៀងខ្លួន ។

**មាត្រា ៧ . -**

ប្រធានអង្គភាព GMS របស់ក្រសួង- ស្ថាប័ននីមួយៗ គឺជាសមាជិករបស់លេខាធិការដ្ឋានជាតិមហាអនុតំបន់មេគង្គ ។

**មាត្រា ៨ . -**

សេចក្តីសំរេចលេខ ១០ សសរ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៧ ស្តីពីការប្រគល់ភារកិច្ចតាមដាននិងសំរបសំរួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់វិសាលភាពទន្លេមេគង្គ និង រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជា និរាករណ៍ ។

**មាត្រា ៩ . -**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃបណ្តាក្រសួង- ស្ថាប័នពាក់ពន្ធ័ទាំងអស់ និងសាមីខ្លួន ដូចមានចែងក្នុង មាត្រា ១ និង មាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូន ឯកឧត្តម អស់លោក លោកស្រី ចំនួន ៧៩រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចជួយប្រជារាស្ត្រ ដែលរងគ្រោះដោយសារទឹកជំនន់កន្លងមកដូច មាន រាយនាមខាងក្រោមនេះ ៖

**ក _ មេដាយមាសការងារ**

១-ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការ គជគម
២-ឯកឧត្តម **អ៊ុក ដាមរី** អនុប្រធានទី១ កាកបាទក្រហមកម្ពុជា
៣-ឯកឧត្តម **ហ៊ីម ស្មៀក** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី
៤-ឯកឧត្តម **ហ៊ុន ស៊ីថា** នាយករងខុទ្ទកាល័យ សម្តេច នាយករដ្ឋមន្ត្រី
៥-លោកជំទាវ **សុខ ឡេងបូរ៉ា** នាយិការ ពិធីការសម្តេច នាយករដ្ឋមន្ត្រី
៦-ឯកឧត្តម **ម៉ុន សំបូរ** ទីប្រឹក្សាសម្តេច នាយករដ្ឋមន្ត្រី
៧-ឯកឧត្តម **ស្រ៊ី ថាមរុង** ទីប្រឹក្សាសម្តេច នាយករដ្ឋមន្ត្រី

៨-ឯកឧត្តម ច្រាក់ សុខុន ឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសបារាំង

៩-លោក ស្លារ៉េ សុភាព សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១០-លោក ជា យុពា សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១១-លោក នួន ម្ចូពិណ្ណរា សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១២-លោក ជា សារឿន សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១៣-លោក អ៊ុក ចន សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១៤-លោកស្រី ទ្រី សុខា សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១៥-លោកស្រី រស់ ចន្ទ្ទផល្លី ពិធីការ សម្តេច នាយករដ្ឋមន្ត្រី

១៦-លោក សុខ សូរិយា ពិធីការ សម្តេច នាយករដ្ឋមន្ត្រី

១៧-លោក សេះ នឿង សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

១៨-លោក ម៉ែន រុន ជំនួយការ សម្តេច នាយករដ្ឋមន្ត្រី

១៩-លោក ឃីម រស្មីជា សមាជិកក្រុមលេខា សម្តេច នាយករដ្ឋមន្ត្រី

២០-លោក ហង្ស សាមឿន អគ្គលេខាធិការរង គ.ជ.គ.ម

២១-លោកជំទាវ ពុំ ចាន់ធានី អគ្គលេខាធិការរងទី១ កាកបាទក្រហមកម្ពុជា

២២-ឯកឧត្តម ជុំ ប៊ុនរ៉ុង អគ្គនាយកមូលនិធិសង្គមនៃព្រះរាជាណាចក្រកម្ពុជា

២៣-ឯកឧត្តម ហ៊ុំ ឆាំងអេង អគ្គលេខាធិការ គណៈកម្មាធិការជាតិទន្លេមេគង្គ

២៤-ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស

២៥-ឧត្តមសេនីយ៍ឯក ខ្វាន់ ស៊ាម មេបញ្ជាការកងវិស្វកម្ម

២៦-ឧត្តមសេនីយ៍ឯក ជា តារា នាយកទីចាត់ការកលយុទ្ធអគ្គមេបញ្ជាការ

២៧-ឧត្តមសេនីយ៍ឯក ម៉ុង សំផន អគ្គនាយកអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញកិច្ចក្រសួងការពារជាតិ

២៨-ឧត្តមនាវីឯក អ៊ុង សំខាន់ មេបញ្ជាការកងទ័ពជើងទឹក

២៩-ឧត្តមសេនីយ៍ឯក ស៊ឹង សំណាង មេបញ្ជាការកងទ័ពអាកាស

៣០-ឧត្តមសេនីយ៍ទោ ស៊ុំ សំណាង អគ្គនាយករងអគ្គនាយកដ្ឋានភស្តុភារហិរញ្ញកិច្ច ក្រសួងការពារជាតិ

៣១-ឧត្តមសេនីយ៍ត្រី ពៅ ផារី មេបញ្ជាការរងវិស្វកម្ម

៣២-ឧត្តមសេនីយ៍ត្រី សែម សុវណ្ណានី មេបញ្ជាការរងវិស្វកម្ម

៣៣-ឧត្តមសេនីយ៍ត្រី សួង ឃុន្នី មេបញ្ជាការរងវិស្វកម្ម

៣៤-ឧត្តមសេនីយ៍ត្រី ជា សុខលាង មេបញ្ជាការរងវិស្វកម្ម

៣៥-លោក ម៉ុន ណោរិទ្ធិ ប្រធាននាយកដ្ឋាន សំរបសំរួលសង្គ្រោះបន្ទាន់ និង ស្តារឡើងវិញ

៣៦-លោ លឹម ស៊ីដេនីន ប្រធាននាយកដ្ឋានផ្លូវថ្នល់ក្រសួងសាធារណៈការ

៣៧-លោកវេជ្ជបណ្ឌិត អ៊ុយ សំអាត ប្រធាននាយកដ្ឋានសុខាភិបាលគ្រោះមហន្តរាយ
សមាគមជាតិកាកបាទក្រហមកម្ពុជា

៣៨-លោកស្រីវេជ្ជបណ្ឌិត ឃួន អេងមុន្នី អនុប្រធាននាយកដ្ឋានក្រសួងសុខាភិបាល

៣៩-លោក នូច ឡេង ប្រធាននាយកដ្ឋាន ថវិកានីយកម្ម និងហិរញ្ញកិច្ច

៤០-លោក ម៉ម ប៊ុន អនុប្រធាននាយកដ្ឋាន ហិរញ្ញកិច្ច

៤១-លោក ឌី សុគីន ប្រធាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ច គជគម

៤២-លោក ឡាំ ហេងហួត អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ

៤៣-លោក កែង គឹមឈាង អនុប្រធាននាយកដ្ឋានសន្តិសុខ ក្រសួងមហាផ្ទៃ

៤៤-លោក ឃួន យា អនុប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញកិច្ច

៤៥-លោក ទល្ង សំបុក ប្រធានការិយាល័យ អាកាសចរស៊ីវិល

៤៦-លោក ប៊ុច ឈាងហ៊ី លេខាអចិន្ត្រៃយ៍ គគម ខេត្តកណ្តាល

៤៧-លោក និស ប៉ៃប អនុប្រធាននាយកដ្ឋានគាំពារការពារគ្រោះបន្ទាន់
និងស្តារឡើងវិញ

៤៨-លោក នួន ប៊ូលីន លេខាអចិន្ត្រៃយ៍ គគម ខេត្តកំពង់ចាម

៤៩-អ្នកស្រី ត្រឹង ថាវី លេខាអចិន្ត្រៃយ៍ គគម ខេត្តក្រចេះ

៥០-លោក ថាក់ ការិតាន់ លេខាអចិន្ត្រៃយ៍ គគម ខេត្តស្ទឹងត្រែង

៥១-លោក ទេព បូរី លេខាអចិន្ត្រៃយ៍ គគម ខេត្តព្រៃវែង

៥២-លោក គឹម ឆា លេខាអចិន្ត្រៃយ៍ គគម ខេត្តស្វាយរៀង

៥៣-លោក ខូយ សុខា លេខាអចិន្ត្រៃយ៍ គគម ខេត្តពោធិសាត់

៥៤-លោក ឥន្ទ ឈឿន លេខាអចិន្ត្រៃយ៍ គគម ខេត្តកំពត

៥៥-លោក ទេស ហ៊ាញ លេខាអចិន្ត្រៃយ៍ គគម ខេត្តបាត់ដំបង

៥៦-លោក ស្រី ចេន លេខាអចិន្ត្រៃយ៍ គគម ខេត្តតាកែវ

៥៧-លោក ឡៀប ពីរ លេខាអចិន្ត្រៃយ៍ គគម ខេត្តកំពង់ធំ

៥៨-លោក ម៉ែន សំបូរ លេខាអចិន្ត្រៃយ៍ គគម ខេត្តកំពង់ស្ពឺ

៥៩-លោក នូច ហ៊ីម លេខាអចិន្ត្រៃយ៍ គគម ខេត្តកំពង់ឆ្នាំង

៦០-លោក គុប សារឿង លេខាអចិន្ត្រៃយ៍ គគម ខេត្តបន្ទាយមានជ័យ

៦១-លោក ម៉ាន់ ឈឿន លេខាអចិន្ត្រៃយ៍ រាជធានីភ្នំពេញ

៦២- លោក ឆេង អូន ជំនួយការ អនុប្រធានទី១ គ.ជ.គ.ម

៦៣- លោក ឈាង ណាក់ មន្ត្រីមូលនិធិសង្គម នៃព្រះរាជាណាចក្រកម្ពុជា

៦៤- លោក អាំ នរិទ្ធ អនុប្រធាននាយកដ្ឋានអភិរក្សធនធានទឹក

៦៥- លោក កែវ ទី ជំនួយការ អនុប្រធានទី១ គ.ជ.គ.ម

៦៦- លោក ឃុន សុខា ជំនួយការ អនុប្រធានទី១ គ.ជ.គ.ម

៦៧- លោក នាង ឆែន អនុប្រធាននាយកដ្ឋាន សំបសំរួល គ.ជ.គ.ម

ខ. មេដាយប្រាក់ការងារ :

១- លោក ឃ្វាំង ខ្លូត ប្រធាន ការិយាល័យ គ.ជ.គ.ម

២- លោក អ៊ុ ចាន់ឌី ប្រធានការិយាល័យ គ.ជ.គ.ម

៣- លោក ម៉ុង សិត អនុប្រធានការិយាល័យក្រសួងសាធារណការនិងដឹកជញ្ជូន

៤- លោក ញ៉ែក ប៊ុនរិទ្ធ អនុប្រធាននាយកដ្ឋាន ហិរញ្ញវត្ថុ

៥- លោក នួន ម៉ុនថុល ទូរទស្សន៍ជាតិកម្ពុជាប្រចាំការ គ.ជ.គ.ម

៦- លោក ធីវថា ដេត ទូរទស្សន៍ជាតិកម្ពុជាប្រចាំការ គ.ជ.គ.ម

៧- លោក និង សាវ៉ាន់ ប្រធានក្រុមត្រួតពិនិត្យហិរញ្ញកិច្ច

គ. មេដាយសំរឹទ្ធការងារ :

១- លោក គុណា ធីរៈ មន្ត្រី គ.ជ.គ.ម

២- លោក ម៉ី ធីរត្ន មន្ត្រី គ.ជ.គ.ម

៣- វរសេនីយ៍ឯក ម៉ែន សំអន មន្ត្រី គ.ជ.គ.ម

៤- លោក អោម អួន មន្ត្រី គ.ជ.គ.ម

៥- លោក អ៊ុំ តួច មន្ត្រី គ.ជ.គ.ម

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៚៚៚*៚៚៚

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤០៧០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ជូន ឧកញ៉ា ចំនួន ០៨ រូប ដែលបានខិតខំចូលរួមយ៉ាងសកម្ម ក្នុងការផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ប្រជារាស្ត្រ ដែលរងគ្រោះដោយសារ ទឹកជំនន់ក្នុងឆ្នាំ ២០០១ ព្រមទាំងបានរួមចំណែកក្នុងការស្តារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចមានរាយនាមខាងក្រោមនេះ ៖

**ក . មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ**

១ - ឧកញ៉ា **សុខ គង់**

២ - ឧកញ៉ា **ថេង ប៊ុនម៉ា**

៣ - ឧកញ៉ា **ម៉ែន សារុន**

ខ ~ មេដាយសុវត្ថារា ថ្នាក់ សេនា

១ - ឧកញ៉ា ម៉ុង ឫទ្ធី

២ - ឧកញ៉ា គង់ ទ្រឹប

៣ - ឧកញ៉ា គិត ម៉េង

៤ - ឧកញ៉ា ឡាវ ម៉េងឃីន

៥ - ឧកញ៉ា អ៊ុង ប៊ុនហួរ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និងមាត្រា ២
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧១ អនក្រ.បក

## អនុក្រឹត្យ

**ស្តីពីការជូនមេដាយ ស្ថាបនាជាតិ**

******

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនក្រុមហ៊ុន សប្បុរសជន និងអង្គភាព ដែលបានបរិច្ចាកធនធានជួយដល់ប្រជារាស្ត្ររងគ្រោះដោយទឹកជំនន់ឆ្នាំ២០០១ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាស ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ជា សុផារ៉ា** | អង្ករចំនួន | ១០០ តោន |
| ២- ឯកឧត្តម | **ហុក ឡុងឌី** | អង្ករចំនួន | ១០០ តោន |
| ៣- ឯកឧត្តម | **កែ គឹមយ៉ាន** | អង្ករចំនួន | ១០០ តោន |
| ៤- ឧកញ៉ា | **ជួង ឈឹច** | អង្ករចំនួន | ១០០ តោន |
| ៥- ឧកញ៉ា | **ស្រី ខ្ចួន** | អង្ករចំនួន | ១០០ តោន |
| ៦- ឧកញ៉ា | **អាន សំអុល** | អង្ករចំនួន | ១០០ តោន |
| ៧- ឧកញ៉ា | **សំ អាង** | អង្ករចំនួន | ១០០ តោន |

| | | |
|---|---|---|
| ៨- លោក GOH CHIEH | ក្រុមហ៊ុនហ្គេត | ថវិកាចំនួន ២០ ០០០ ដុល្លាអាមេរិក |
| ៩- លោក ង៉ាង ណាំ TIMAS RESOURCES | | ថវិកាចំនួន ២១ ០០០ ដុល្លាអាមេរិក |
| ១០- លោក ឡាយ ជុនហួរ | ក្រុមហ៊ុន Kingwood Industry | អង្ករចំនួន ១០០ តោន |
| ១១- លោក KOH POH TIONG Asia Pacific Breweries L.T.D | | ថវិកាចំនួន ៥០ ០០០ ដុល្លាអាមេរិក |
| ១២- សមាគមខ្មែរ-ចិន នៅរដ្ឋកាលីហ្វ័រនីញ៉ា USA | | អង្ករចំនួន ១០០ តោន<br>ម្សៅសាប៊ូ ២ តោន |
| ១៣- លោក ANTOINE ZACHARIAS | ក្រុមហ៊ុនវ៉ាំងស៊ី SCA អាកាសយានដ្ឋាន | ថវិកាចំនួន ៥៤ ០០០ ដុល្លាអាមេរិក |
| ១៤- លោក Tan Sri Dr. Chen Lip Keong | ក្រុមហ៊ុន Ariston. Sdn. Bhd | ថវិកាចំនួន ២០ ០០០ ដុល្លាអាមេរិក |
| ១៥- លោក ស គង់ | សមាគមអាជីវករម៉ាស៊ីនស្រូវ សៀមរាប | អង្ករចំនួន ១០០ តោន |
| ១៦- លោក R David Cohen | ក្រុមហ៊ុន TFI Holding | អង្ករចំនួន ១០០ តោន |
| ១៧- លោក ង៉ី ស៊ីវេង | ក្រុមហ៊ុន ធរីបុង អន្តរជាតិ | អង្ករចំនួន ១០០ តោន |
| ១៨- លោក GENE CHOI SLD Telcom Ptc.Co.LTD | | ថវិកាចំនួន ១២ ០០០ ដុល្លាអាមេរិក |
| ១៩- លោក CLEMENTKER CHENG YANG | ក្រុមហ៊ុន MANHATAN | ថវិកាចំនួន ១០ ០០០ ដុល្លាអាមេរិក |
| ២០- លោក ពុង ឃាងសៃ | ធនាគារកាណាឌីយ៉ា | ថវិកាចំនួន ១០ ០០០ ដុល្លាអាមេរិក |
| ២១- ទីចាត់ការគយ និងរដ្ឋាករ | | ថវិកាចំនួន ១០ ០០០ ដុល្លាអាមេរិក |
| ២២- ភ្នាក់ងារ កម្ពុជា នាវាចរ កាំហេប | | ថវិកាចំនួន ១០០ ០០០ ០០០ រៀល |

## ខ_ ខេត្តព្រះសីហនុ ... 

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | សុខ អាន | និងលោកជំទាវ | អង្ករចំនួន ៥០ តោន |
| ២- ឯកឧត្តម | យឹម ឆៃលី | | អង្ករចំនួន ៥០ តោន |
| ៣- ឯកឧត្តម | ឯម សំអាន | | អង្ករចំនួន ៥០ តោន |
| ៤- ឯកឧត្តម | ស៊ូ យុន | | អង្ករចំនួន ៥០ តោន |
| ៥- លោក | ថោង សារ៉ាត់ | នាយកសហគមន៍ អភិវឌ្ឍន៍សន្តិភាព | អង្ករចំនួន ៥០ តោន |
| ៦- ឧកញ៉ា | ជា ស៊ឿន | ក្រុមហ៊ុន តាកហ្វាកហ្គាមិន | អង្ករចំនួន ៥០ តោន |
| ៧- កំពង់ផែ ស្វយ័ត ក្រុងព្រះសីហនុ | | | ថវិកាចំនួន ៥ ០០០ ដុល្លាអាមេរិក |
| ៨- លោក TOM KWOK ទីប្រឹក្សាពាណិជ្ជកម្ម ក្រុមហ៊ុន BHP Lilliton | | | ថវិកាចំនួន ៥ ០០០ ដុល្លាអាមេរិក |

## គ_ មេដាយ សេរីវឌ្ឍន៍ ស្ថាបនាជាតិ

| | | |
|---|---|---|
| ១- ឯកឧត្តម | ឃី តាំងលីម | អង្ករចំនួន ២០ តោន |
| ២- ឯកឧត្តម | ចម ប្រសិទ្ធ | អង្ករចំនួន ២០ តោន |

| | | |
|---|---|---|
| ៣- ឯកឧត្តម | អ៊ិត សំហេង | អង្ករចំនួន ២០ តោន |
| ៤- ឯកឧត្តម | ចំរុន្ទ សារុន | អង្ករចំនួន ២០ តោន |
| ៥- ឯកឧត្តម | លឹម គានហោ | អង្ករចំនួន ២០ តោន |
| ៦- ឯកឧត្តម | ត្រាំ អ៊ីវតឹក | អង្ករចំនួន ២០ តោន |
| ៧- ឧកញ៉ា | សូ សុវណ្ណ | អង្ករចំនួន ២០ តោន |
| ៨- ឧកញ៉ា | ឡុង ហ៊ីង | អង្ករចំនួន ២០ តោន |
| ៩- ឯកឧត្តម | ស៊ុយ សែម | អង្ករចំនួន ២០ តោន |
| ១០- សាលាខេត្ត កណ្ដាល | | អង្ករចំនួន ២០ តោន |
| ១១- ឧកញ៉ា | គង់ ឫទ្ធិជាតិ | ថវិកាចំនួន ៣ ៦០០ ដុល្លាអាមេរិក |
| ១២- ឧកញ៉ា | អ៊ុក វ៉ាប៊ុន | អង្ករចំនួន ២០ តោន |
| ១៣- ឯកឧត្តម | ស្វួន សិទ្ធី | អង្ករចំនួន ២០ តោន |
| ១៤- ក្រុមហ៊ុន | ចំការកៅស៊ូជប់ | ថវិកាចំនួន ៣ ៦០០ ដុល្លាអាមេរិក |
| ១៥- ក្រុមហ៊ុន | ចំការកៅស៊ូព្រែក | ថវិកាចំនួន ៣ ៦០០ ដុល្លាអាមេរិក |
| ១៦- រាជាយស្វ័យយាន កម្ពុជា | | អង្ករចំនួន ២០ តោន |
| ១៧- លោក | ឌី សុគន្ធ | អង្ករចំនួន ២០ តោន |
| ១៨- សហគ្រាស កូឡិចស៊ីម | | ថវិកាចំនួន ៤ ០០០ ដុល្លាអាមេរិក |
| ១៩- លោក | លី ម៉ុងហៃ ក្រុមហ៊ុន ញូភាញ៉ូវីលគ្រេត កម្ពុជាចំកាត់ | ថវិកាចំនួន ៤ ០០០ ដុល្លាអាមេរិក |
| ២០- ក្រុមហ៊ុន | ចំការកៅស៊ូមេមត់ | ថវិកាចំនួន ២ ៧០០ ដុល្លាអាមេរិក |
| ២១- ក្រុមហ៊ុន | ចំការកៅស៊ូបឹងកេត | ថវិកាចំនួន ២ ៧០០ ដុល្លាអាមេរិក |
| ២២- ក្រុមហ៊ុន | ចំការកៅស៊ូអណ្ដូង | ថវិកាចំនួន ២ ៧០០ ដុល្លាអាមេរិក |
| ២៣- ក្រុមហ៊ុន | ចំការកៅស៊ូពាម ជាំង | ថវិកាចំនួន ២ ៧០០ ដុល្លាអាមេរិក |
| ២៤- ឯកឧត្តម | ម៉ុក ម៉ារ៉េត | អង្ករចំនួន ១០ តោន |
| ២៥- ឯកឧត្តម | ឆាយ ថន | អង្ករចំនួន ១០ តោន |
| ២៦- ឯកឧត្តម | ចំរុន្ទ តុង អ៊ុំ | អង្ករចំនួន ១០ តោន |
| ២៧- ឯកឧត្តម | អ៊ុំ គឹមហ៊ាង | អង្ករចំនួន ១០ តោន |
| ២៨- ឯកឧត្តម | មាស សុភា | អង្ករចំនួន ១០ តោន |
| ២៩- ឯកឧត្តម | អ៊ុំ រុន | អង្ករចំនួន ១០ តោន |
| ៣០- ឯកឧត្តម | ខៀវ សុធី | ថវិកាចំនួន ១ ៨០០ ដុល្លាអាមេរិក |
| ៣១- លោក ឧត្តមសេនីយ៍ត្រី | គង់ អឿង | ថវិកាចំនួន ១ ៨០០ ដុល្លាអាមេរិក |

៣២- ក្រុមហ៊ុន ចំការកៅស៊ូស្នួល ស្រូវពូជ ២០ តោន ថវិកាចំនួន ៩០០ ដុល្លាអាមេរិក

៣៣- ឯកឧត្តម តាន់ សេងហួរ អង្ករចំនួន ១០ តោន

៣៤- ឯកឧត្តម អ៊ួន ព័ន្ធមុនីរ័ត្ន ថវិកាចំនួន ១ ៨០០ ដុល្លាអាមេរិក

៣៥- ឧកញ៉ា ស៊ីវមុន្នី អង្ករចំនួន ១០ តោន

៣៦- ក្រុមហ៊ុន សាយម៉ិច ទំហរណ៍ អាហារណ៍ ថវិកាចំនួន ៣ ៦០០ ដុល្លាអាមេរិក

៣៧- លោក អ៊ុំ ឆៃខួន ផលិតកម្មស្ករហង្សមាស អង្ករចំនួន ១១ តោន

មីចំនួន ១០០ កេសធំ

៣៨- នាយកដ្ឋាន រុក្ខាប្រមាញ់ អង្ករចំនួន ១៤ តោន

៣៩- លោក ឌី ចូច អង្ករចំនួន ១០ តោន

៤០- នាយកដ្ឋាន ជលផល ថវិកាចំនួន ១ ៦៧៨ ដុល្លាអាមេរិក និង ៣ ៤៦៨ ០០០ រៀល

៤១- អគ្គិសនី កម្ពុជា ថវិកាចំនួន ១០ លានរៀល

៤២- នាយកដ្ឋាន ពន្ធដារ ថវិកាចំនួន ៦ លានរៀល

៤៣- ឯកឧត្តម អ៊ិត ប្រាំង ថវិកាចំនួន ១ ៥០០ ដុល្លាអាមេរិក

៤៤- លោក គង់ សាង ក្រុមហ៊ុន QMI Industrial Co., Ltd. អង្ករចំនួន ១០ តោន

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**កន្លែងទទួល**</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និងមាត្រា ២
- រាជកិច្ច

កាលប្បវត្តិ-ឯកសារ

HI.MD.LCN.20

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧២ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកស្រី រស់ ស៊ីម៉ារ៉ា បច្ចុប្បន្នអនុប្រធាននាយកដ្ឋានអាស៊ី ប៉ាស៊ីហ្វិក នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

ចំលងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ...៧៦...សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជា នាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ៧ និងកិច្ចប្រជុំកំពូលអាស៊ាន + ៣ នៅប្រទេសប្រ៊ុយណេ ដារូសាឡាម ចាប់ពីថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ រហូតដល់សម្តេចនាយករដ្ឋមន្ត្រីអញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ២ (ដើម្បីអនុវត្ត)*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧ សសរ

## សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ៦៦សសរ ចុះថ្ងៃទី០២ខែ វិច្ឆិកា ឆ្នាំ២០០១ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីក្រសួងផែនការជារដ្ឋមន្ត្រីស្តីទីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ជំនួសឯកឧត្តម អ៊ឹម ឈុនលឹម ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចនៅព្រះរាជាណាចក្រថៃឡង់ដ៍ ចាប់ពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០១ រហូតដល់ពេលឯកឧត្តម អ៊ឹម ឈុនលឹម អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម ឆាយ ថន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រីស្តីទី

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

ស ៧៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** ៩៨.សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការផ្ទេរសិទ្ធិរដ្ឋមន្ត្រីស្តីទី

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០១

## សំរេច

**ប្រការ១ .-**

ផ្ទេរសិទ្ធិជូនឯកឧត្តម **ស៊ុំ ម៉ានិត** រដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជារដ្ឋមន្ត្រីស្តីទី នៃក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជំនួសឯកឧត្តម **អ៊ិត សំហេង** ដែលត្រូវអញ្ជើញទៅបំពេញបេសកម្មនៅប្រទេសជប៉ុន ដោយគិតចាប់ពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០១រហូតដល់ឯកឧត្តម **អ៊ិត សំហេង** អញ្ជើញវិលត្រឡប់មកវិញ ។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាលអភិបាលខេត្ត-ក្រុង និងឯកឧត្តម **ស៊ុំ ម៉ានិត** ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចប្រការ២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៦៥ សសរ

# សេចក្តីសំរេច

## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** ៖ ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រថៃ ចាប់ពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ រហូតដល់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. [illegible] MoC / M 2001

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស

**ស្តីពី**

**ស្ថានភាពរោងចក្រកាត់ដេរ Santex Industry (Cambodia) Limited**

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ចាត់ទុករោងចក្រកាត់ដេរកាបូប **Santex Industry (Cambodia) Limited** ដែលលែងមានដំណើរការ ហើយ កម្មករត្រូវបានបញ្ឈប់ពីការងារ ថាបាន បិទទ្វារជាស្ថាពរ ។

រោងចក្រកាបូបនេះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់ គេនឹងត្រូវឆូត

ពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋាននីតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេ ចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះ ពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនីតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារី
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No ... MoC / M 2001

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ស្ថានភាពរោងចក្រកាត់ដេរមួយចំនួន
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រក្រ/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងតាមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស , រោមចៀម , សរសៃសប្បនិម្មិតធ្វើដោយដៃមនុស្ស , សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាល កម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩
- យោងលិខិតរបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ចុះថ្ងៃទី ០៤-១០-២០០០
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ចាត់ទុករោងចក្រកាត់ដេរសំលៀកបំពាក់ដូចខាងក្រោម ដែលលែងមានដំណើរការ ហើយកម្មករត្រូវបានបញ្ឈប់ពីការងារ ថាបានបិទទ្វារជាស្ថាពរ :

**1- Join Right (Cambodia) Knitting Factory Ltd.**

រោងចក្រកាត់ដេរសំលៀកបំពាក់នេះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែកកូតាផ្សេងៗ (បើមាន) នឹងត្រូវលុប ចេញ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មនឹងត្រូវឆូតពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ចាត់ទុកថាបាន បិទទ្វារជាបណ្តោះអាសន្ន រោងចក្រកាត់ដេរសំលៀកបំពាក់ដូចខាងក្រោម ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅ រក្សាដដែលហើយកម្មករត្រូវបានបញ្ឈប់ពីការងារជាបណ្តោះអាសន្ន :

**1- Far East Textiles Ltd.**
**2- Henan (Cambodia) Garment International Co., Ltd.**
**3- P.P.S. Limited (Cambodia)**
**4- Samford Garment Cambodia Ltd.**
**5- Willing Garment Knitting FTY Ltd.**

រោងចក្រកាត់ដេរសំលៀកបំពាក់ទាំងនោះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែកកូតាផ្សេងៗ (បើមាន) នឹងត្រូវផ្អាក ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធនាំចេញសាជាថ្មី ប្រសិនបើរោងចក្រទាំងនោះបន្តសកម្មភាពរបស់ ខ្លួនវិញក្នុងរយះពេល ៣ ខែបន្ទាប់ ហើយកូតាឆ្នាំ ២០០១ ជាមូលដ្ឋាន នឹងត្រូវបានប្រគល់ជូនវិញ ។ ប្រសិន បើរោងចក្រទាំងនោះមិនបានបន្តសកម្មភាពរបស់ខ្លួនក្នុងរយះពេល ៣ ខែបន្ទាប់ រោងចក្រទាំងនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូត ពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ៣ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតិយជន នៅកម្ពុជា ព្រមទាំងបំណុលរបស់គេ ចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**<u>ប្រការ</u> ៤ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ និង ២ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ៧៩០ MoC / M 2001

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០១

**ប្រកាស**

**ស្តីពី**

**ស្ថានភាពរោងចក្រ Intech Footwear Industry Co., Ltd.**

*****

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួង ពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញសំណើរបស់ក្រុមហ៊ុន Intech Footwear Industry Co., Ltd.
- បានឃើញការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ក្រុមហ៊ុន **Intech Footwear Industry Co., Ltd.** ដែលចាត់ទុកជាបិទទ្វារ បណ្តោះអាសន្ន តាមប្រកាសលេខ ២៤០ MOC / M 2001 ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ត្រូវបានអនុញ្ញាតិអោយដំណើរការផលិតកម្ម និង ធ្វើនិហរណកម្ម ឡើងវិញជាធម្មតា ។

**ប្រការ ២ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានរាជទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមស្បែកជើងកម្ពុជា
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

ភ្នំពេញ. ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០១

លេខ : ២៨២ សកបយ.

# ប្រកាស

## ស្តីពី

## ប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើកម្មករនិយោជិតចាប់ពីប្រាំបីនាក់ឡើងទៅ ត្រូវបង្កើតអោយមានប្រតិភូបុគ្គលិក។

ប្រតិភូពេញសិទ្ធិ ( ឬប្រតិភូបុគ្គលិកពេញសិទ្ធិ) ម្នាក់ត្រូវមានប្រតិភូជំនួយម្នាក់។

ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលត្រូវអោយមានប្រតិភូបុគ្គលិកជាដាច់ខាតគឺសហគ្រាស គ្រឹះស្ថានឧស្សាហកម្ម ពាណិជ្ជកម្ម រ៉ែ សំណង់ សេវា ធនាគារ កសិកម្ម កំពង់ផែ សណ្ឋាគារ ភោជនីយដ្ឋាន សាលាបង្រៀន និងផលិតកម្មផ្សេងៗទៀត។ ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវបោះឆ្នោតជ្រើសរើសដោយ

កម្មករនិយោជិតសំរាប់អាណត្តិពីរឆ្នាំ ។

**ប្រការ២.-** បែបបទ និងរបៀបបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវអនុវត្តដូចតទៅ :-

-សហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស គ្រឹះស្ថាន ជាអ្នកជ្រើសតាំងបេក្ខជនឈរឈ្មោះទៅតាមចំនួនអាសនៈ នៃប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ និយោជកត្រូវពិភាក្សាជាមួយសហជីពទាំងនោះដើម្បីកំណត់បែបបទ កាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅអោយគណៈអ្នកបោះឆ្នោត ។

-នៅពេលដែលមិនទាន់មានសហជីពនៅក្នុងសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតមានសិទ្ធិពេញលេញដោយស្ម័គ្រចិត្តចុះឈ្មោះក្នុងបញ្ជីបេក្ខជន ដើម្បីអោយគេបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិនិងប្រតិភូជំនួយ ។ និយោជកត្រូវអញ្ជើញតំណាងកម្មករនិយោជិតដើម្បីពិភាក្សាគ្នាអំពីបែបបទចាត់តាំង កាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅអោយគណៈអ្នកបោះឆ្នោត ។

-ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិជំនួយត្រូវធ្វើតាមរបៀបតែមួយ ប៉ុន្តែត្រូវធ្វើដាច់ដោយឡែកពីគ្នា។ ការបោះឆ្នោតត្រូវធ្វើដោយសម្ងាត់ ។ ការបោះឆ្នោតត្រូវធ្វើក្នុងម៉ោងធ្វើការ ។

- សហគ្រាស គ្រឹះស្ថានណាមានកម្មករនិយោជិតចាប់ពី ៥១ នាក់ ( ហាសិបមួយនាក់ ) ឡើងទៅការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយត្រូវបែងចែកជាពីរគណៈដាច់ដោយឡែក ។ គណៈអ្នកបោះឆ្នោតទី ១ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងអោយកម្មករនិយោជិតធម្មតា ។ គណៈអ្នកបោះឆ្នោតទី ២ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងអោយអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើង និងអ្នកជំនាញជាន់ខ្ពស់ ។ ប៉ុន្តែបើចំនួនសរុប នៃអ្នកត្រូវបោះឆ្នោតក្នុងគណៈអ្នកបោះឆ្នោតទី ២ មានតិចជាងប្រាំបីនាក់នោះ ការបោះឆ្នោតអាចប្រព្រឹត្តទៅតែមួយគណៈរួមគ្នាតែម្តង ។

-និយោជកត្រូវបិទផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជូនដល់កម្មករនិយោជិតបានជ្រាប យ៉ាងតិចក្នុងរយៈពេលបីថ្ងៃមុនថ្ងៃបោះឆ្នោត ។

-អ្នកបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្ត ប៉ុន្តែត្រូវគោរពបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជាដាច់ខាត ។

-ក្រោយពេលប្រកាសផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះរួច មុននិងចែកសន្លឹកឆ្នោតដល់កម្មករនិយោជិតធ្វើការបោះឆ្នោត អ្នកទទួលខុសត្រូវរៀបចំការបោះឆ្នោតត្រូវអនុញ្ញាតអោយកម្មករនិយោជិតសម្រាករយៈពេលពីរម៉ោងដើម្បីធ្វើការត្រិះរិះពិចារណាដោយសេរីទៅលើបេក្ខជនដែលខ្លួនពេញចិត្ត ។

-ចំពោះសហគ្រាស គ្រឹះស្ថានដែលមានសាខាច្រើនហើយសាខានីមួយៗមានកម្មករនិយោជិតចាប់ពី

ប្រាំបីនាក់ឡើងទៅត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយតាមសាខានីមួយៗ ដាច់ដោយឡែកពីគ្នា។

-ក្នុងករណីបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិថ្មី ការបោះឆ្នោតត្រូវប្រព្រឹត្តទៅក្នុងរយៈពេលដប់ប្រាំថ្ងៃមុនពេលបញ្ចប់អាណត្តិប្រតិភូបុគ្គលិក។

-និយោជកត្រូវទទួលខុសត្រូវការរៀបចំបោះឆ្នោតនេះ ទាំងផ្នែកសំភារៈ ហិរញ្ញវត្ថុ និងស្មារតី។

**ប្រការ៣.-** ប្រតិភូបុគ្គលិកក្នុងនាមជាតំណាងស្របច្បាប់របស់កម្មករនិយោជិត ត្រូវបំពេញភារៈកិច្ចរបស់ខ្លួនអោយបានត្រឹមត្រូវ និងស្មោះត្រង់។

ប្រតិភូបុគ្គលិកមានបេសកកម្មជាអាទិ៍ :

-នាំពាក្យប្រាប់និយោជកអំពីសេចក្តីតវ៉ារបស់កម្មករនិយោជិតម្នាក់ៗ ឬច្រើននាក់រួមគ្នា ដែលមិនសុខចិត្តអំពីការអនុវត្តន៍ប្រាក់ឈ្នួល ការអនុវត្តន៍នីតិក្រម និងបទបញ្ជាទូទៅនៃការងារ ហើយនឹងអនុសញ្ញារួមសំរាប់អនុវត្តនៅក្នុងសហគ្រាស គ្រឹះស្ថាន

-ជំរាបជូនអធិការការងារនូវបណ្តឹងតវ៉ាមិនសុខចិត្ត និងការរិះគន់ផ្សេងៗពាក់ព័ន្ធដល់ការអនុវត្តន៍បទប្បញ្ញត្តិច្បាប់ និងបទបញ្ជាការងារដែលអធិការការងារមានភារកិច្ចត្រួតពិនិត្យ

-មើលខុសត្រូវលើការអនុវត្តន៍បទប្បញ្ញត្តិខាងអនាម័យ និងខាងសន្តិសុខការងារ

-លើកសំណូមពរនូវវិធានការដែលមានប្រយោជន៍ សំរាប់រួមចំណែកការពារសុខភាព កែលំអសន្តិសុខ និងល័ក្ខខ័ណ្ឌការងាររបស់កម្មករនិយោជិតដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថាន ពិសេសក្នុងករណីមានគ្រោះថ្នាក់ការងារ ឬមានជំងឺវិជ្ជាជីវៈ។

-ជូនយោបល់ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង ឬលើគម្រោងនៃការកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន។

-ជូនយោបល់ជាលាយលក្ខណ៍អក្សរលើវិធានការដែលគេបានគ្រោងឡើងសំរាប់ការបញ្ឈប់កម្មករនិយោជិតដោយសារកាត់បន្ថយសកម្មភាព ឬការរៀបចំផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន។

**ប្រការ៤.-** និយោជកត្រូវធ្វើកំណត់ហេតុនៅរាល់ពេលធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ។ ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅរាជធានីភ្នំពេញ ត្រូវផ្ញើកំណត់ហេតុនេះមួយច្បាប់ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដែលស្ថិតនៅអាគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក ( ផ្លូវលេខ១៨៤ ) សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញរាជធានីភ្នំពេញ។ ចំពោះសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត - ក្រុង ត្រូវផ្ញើកំណត់ហេតុនេះមួយច្បាប់ទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុង នៃមូលដ្ឋានខ្លួន។ កំណត់ហេតុនេះ ត្រូវផ្ញើយ៉ាងយូរបំផុតក្នុងរយៈពេលប្រាំបីថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត។

**ប្រការ៥.-** និយោជកត្រូវផ្តល់អោយប្រតិភូបុគ្គលិក នូវទីកន្លែងធ្វើការ ទីកន្លែងប្រជុំ សំភារៈធ្វើការ និងទីកន្លែងសំរាប់ការបិទផ្សាយផ្សេងៗ ដ៏ស្រមស្រប ។

**ប្រការ៦.-** និយោជកត្រូវអនុញ្ញាតអោយប្រតិភូបុគ្គលិកម្នាក់ៗ នូវពេលវេលាពីរម៉ោងក្នុងមួយសប្តាហ៍ សំរាប់បំពេញការងាររបស់ខ្លួន ដោយរក្សាទុកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំផ្សេងៗ ដែលធ្លាប់បានទទួលនៅដដែល ។ ក្នុងករណីពិសេស និងដោយមានការឯកភាពពីនិយោជកផង ប្រតិភូបុគ្គលិកម្នាក់ៗ អាចបំពេញការងាររបស់ខ្លួនលើសពីថិរវេលាកំណត់នេះ ។

**ប្រការ៧.-** កម្មករនិយោជិតអាចបណ្តេញប្រតិភូបុគ្គលិកពីតំណែងមុនពេលចប់អាណត្តិបាន ក្នុងករណីដែលប្រតិភូ-បុគ្គលិកនោះមិនបានបំពេញភារកិច្ចរបស់ខ្លួន ។ ការសំរេចស្តីពីការបណ្តេញចេញនេះ ត្រូវធ្វើឡើងតាមរបៀប និងបែបបទបោះឆ្នោត ដូចគ្នានឹងពេលជ្រើសរើសជននោះដែរ ។ កម្មករនិយោជិតត្រូវជូនដំណឹងជាផ្លូវការទៅអធិការការងារក្នុងរយៈពេលបីថ្ងៃយ៉ាងយូរក្រោយពីពេលសំរេចបណ្តេញប្រតិភូបុគ្គលិកចេញពីតំណែង ។ ពេលប្រតិភូពេញសិទ្ធិត្រូវបណ្តេញចេញពីតំណែង ប្រតិភូជំនួយនឹងទទួលការងារនេះជំនួសរហូតដល់ពេលមានការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកសំរាប់អាណត្តិថ្មី ។

**ប្រការ៨.-** ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរបំផុត០៦ខែ ក្រោយពេលបើកសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៩.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៧០ប្រក.អក-ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ លេខ ១៤៦ សកអ-ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ និងលេខ ៦៥៩ សកអ-ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ ២៧៨៧... សកបយ.

ភ្នំពេញ. ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
# ស្តីពី
# បែបបទចុះបញ្ជីកា ការផ្សព្វផ្សាយ និងការត្រួតពិនិត្យ
# ការអនុវត្តន៍អនុសញ្ញារួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## ស ម្រេ ច

**ប្រការ១.-** អនុសញ្ញារួមត្រូវសរសេរជាភាសាខ្មែរ ។ អនុសញ្ញារួមអាចបកប្រែជាភាសាបរទេសបាន ប៉ុន្តែករណីមានវិវាទស្តីពីការបកស្រាយខ្លឹមសារនៃអនុសញ្ញារួម គឺយកភាសាខ្មែរជាផ្លូវការចំពោះមុខច្បាប់ ។

**ប្រការ២.-** អនុសញ្ញារួមត្រូវបញ្ជាក់ច្បាស់អំពីដែនអនុវត្តរបស់ខ្លួន ។ ភាគីហត្ថលេខីត្រូវខិតខំអស់ពីលទ្ធភាព ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវនីតិវិធីទាំងឡាយដែលទាក់ទងនឹងការផ្សះផ្សា ការដោះស្រាយវិវាទតាម

របៈអាជ្ញាកណ្ដាល និងការបកស្រាយអនុសញ្ញារួម ។

**ប្រការ៣.-** លើកលែងតែមានបទបញ្ញត្តិច្បាប់ផ្ទុយពីនេះ អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម មានប្រសិទ្ធិភាពអនុវត្តមួយថ្ងៃបន្ទាប់ពីបានចុះបញ្ជិកានៅស្ថាប័នមានសមត្ថកិច្ច ។ ជនដែលបានចុះហត្ថលេខា ឬជាសមាជិកនៃអង្គការហត្ថលេខី មានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ ។ និយោជកដែលដកសមាជិកភាពចេញពីអង្គការហត្ថលេខី ក្រោយពេលដែលអនុសញ្ញារួមចូលជាធរមាន នៅតែមានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ ។

**ប្រការ៤.-** និយោជក ឬអង្គការរបស់និយោជក ត្រូវយកអនុសញ្ញារួម ព្រមទាំងឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមទៅចុះបញ្ជិកានៅមន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង បើអនុសញ្ញារួមបានចុះហត្ថលេខានៅខេត្ត-ក្រុង ឬនៅនាយកដ្ឋានអធិការកិច្ចការងារ បើអនុសញ្ញារួមបានចុះចុះហត្ថលេខានៅភ្នំពេញ ។ សំណុំលិខិតស្នើសុំចុះបញ្ជិកាមានដូចតទៅ :-

-ពាក្យសុំចុះបញ្ជិកា.......................................................................................... ០១ ច្បាប់

-អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម " បើមាន " ក្នុងមួយមុខ....... ០៥ច្បាប់ ។

**ប្រការ៥.-** បន្ទាប់ពីបានចុះបញ្ជិកាហើយ មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ត្រូវបញ្ជូនអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមមួយមុខមួយច្បាប់ ទៅតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការការងារ ឬការិយាល័យក្រឡាបញ្ជីនៃតុលាការខេត្ត -ក្រុង ក្នុងមូលដ្ឋានខ្លួនបើមិនទាន់មានតុលាការការងារ ។

**ប្រការ៦.-** និយោជកដែលជាប់ទាក់ទិននឹងអនុសញ្ញារួម ត្រូវផ្ដល់សេចក្ដីចម្លងនៃអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម ដែលបានចុះបញ្ជិការួចហើយអោយប្រតិភូបុគ្គលិកមួយច្បាប់ម្នាក់ និងមួយច្បាប់ទៀតអោយការិយាល័យបុគ្គលិកនៃសហគ្រាស គ្រឹះស្ថានសំរាប់ការស្វែងយល់របស់កម្មករនិយោជិតទាំងអស់ ។ ទន្ទឹមនេះ និយោជកត្រូវបិទផ្សាយសេចក្ដីជូនដំណឹងអំពីការធ្វើអនុសញ្ញារួមនេះនៅគ្រប់ទីកន្លែងធ្វើការរបស់កម្មករនិយោជិត និងកន្លែងផ្សព្វផ្សាយពត៌មានដល់កម្មករនិយោជិត ។ ជនគ្រប់រូបអាចស្វែងយល់ដោយឥតគិតថ្លៃអំពីអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមនៅមន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ។ករណីចាំបាច់ គេក៏អាចសុំសេចក្ដីថតចម្លងនៃឯកសារទាំងអស់នេះបាន ដោយគ្រាន់តែបង់ថ្លៃចំពោះការថតចម្លងប៉ុណ្ណោះ ។

**ប្រការ៧.-** អធិការការងារអាចចុះទៅត្រួតពិនិត្យការអនុវត្តន៍អនុសញ្ញារួម ដោយសាកសួរពត៌មានពីប្រតិភូបុគ្គលិកនាយកសហគ្រាស គ្រឹះស្ថាន ឬពីកម្មករនិយោជិតផ្ទាល់ ។

**ប្រការ៨.**- រាល់វិវាទដែលទាក់ទងនឹងការអនុវត្តន៍អនុសញ្ញារួម អាចអោយភាគីណាមួយប្តឹងទៅតុលាការការងារ ឬតុលាការខេត្ត -ក្រុងនៃមូលដ្ឋានដែលអនុសញ្ញារួមបានចុះហត្ថលេខា។ តុលាការអាចសំរេចអោយផ្តល់ជំងឺចិត្តដល់ភាគីដែលមានការខូចខាត។ ប៉ុន្តែភាគីវិវាទអាចប្តឹងទៅអធិការការងារ មានសមត្ថកិច្ចនៅទីកន្លែងដែលភាគីកម្មករនិយោជិតធ្វើការ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

**ប្រការ៩.**- ការចូលរួមអនុវត្តអនុសញ្ញារួមពីសំណាក់និយោជក ឬអង្គការវិជ្ជាជីវៈផ្សេងទៀត ក្រៅពីភាគីហត្ថលេខី និងសមាជិក ក្រោយពេលដែលអនុសញ្ញារួមនេះបានចុះហត្ថលេខារួចហើយក៏ដូចជាការបដិសេធអនុសញ្ញារួម ត្រូវអនុវត្តបែបបទដូចគ្នានឹងការចុះបញ្ជិកា និងផ្សព្វផ្សាយអនុសញ្ញារួមដែរ។

**ប្រការ១០.**- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៤៩ សកអ. ចុះថ្ងៃទី ១៤ ខែ សីហា ឆ្នាំ១៩៩៧ និងលេខ ១៩៧ សកអ.ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១១.**- អនុសញ្ញារួមដែលបានចុះហត្ថលេខារួចហើយមុនការចេញផ្សាយនៃប្រកាសនេះក៏ត្រូវចុះបញ្ជិកា និងផ្សព្វផ្សាយអោយបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសនេះផងដែរ។

**ប្រការ១២.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

រដ្ឋមន្ត្រី

អ៊ិត សំហេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៣៨៤ សកបយ.

ភ្នំពេញ. ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## សេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ចស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ម្រេ ច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលបើកសហគ្រាស គ្រឹះស្ថាន ជាស្ថាពរ ។

**ប្រការ២.-** សំណុំលិខិត នៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានមានដូចតទៅ :-

១-សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានយកតាមគំរូក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ដោយមានបិទតែមប្រិ៍ ១.៥០០រៀល ( មួយពាន់ប្រាំរយរៀល ) ចំនួនពីរច្បាប់។

២-សេចក្តីប្រកាសជូនដំណឹងស្តីអំពីបុគ្គលិកយកតាមគំរូក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ចំនួនបីច្បាប់ ។

ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងរាជធានីភ្នំពេញត្រូវបញ្ជូនសំណុំលិខិតនៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានខាងលើ ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំណែកសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត-ក្រុងផ្សេងទៀត ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។

**ប្រការ៣.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចង្អុលបង្ហាញក្នុងប្រការ១ ខាងលើ ត្រូវជូនដំណឹងមកនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងនៃមូលដ្ឋានខ្លួន នូវគ្រប់សកម្មភាពផ្លាស់ប្តូរទីតាំង ការកែប្រែរចនាសម្ព័ន្ធផលិតកម្ម ការផ្លាស់ប្តូរម្ចាស់ និងការបិទ ឬបញ្ឈប់សកម្មភាពសហគ្រាសយ៉ាងយូរបំផុត៣០ ថ្ងៃ ( សាមសិបថ្ងៃ ) បន្ទាប់ពីថ្ងៃមានការផ្លាស់ប្តូរ ឬបន្ទាប់ពីថ្ងៃដែលបញ្ឈប់សកម្មភាពសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៤.-** អ្នកប្រព្រឹត្តិល្មើសនិងបទបញ្ញត្តិ នៃប្រកាសនេះត្រូវទទួលការពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ១៤៧ សកអ.ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

"ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច
- កាលប្បវត្តិ និងឯកសារ

ភ្ជាប់នឹង
ប្រកាសលេខ ..............
ថ្ងៃទី .......ខែ .........ឆ្នាំ ...........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស

១. យីហោនៃសហគ្រាស..................................................

២. កាលបរិច្ឆេទនៃការបើក , ថ្ងៃទី..................ខែ.........................ឆ្នាំ .....

៣. អាសយដ្ឋានមេទីចាត់ការសហគ្រាស លេខ .................... ផ្លូវ......................... សង្កាត់.................
ខណ្ឌ............................ក្រុង ........................ លេខទូរស័ព្ទ........................... លេខទូរសារ.................
-ឈ្មោះម្ចាស់សហគ្រាស ............................................................ សញ្ជាតិ...............
-ឈ្មោះនាយកសហគ្រាស ............................................................ សញ្ជាតិ...............

៤. សកម្មភាពពិតប្រាកដរបស់សហគ្រាស (១) ..................................................

៥. ប្រភេទសហគ្រាស (២) ..................................................

៦. ទីតាំងនៃសហគ្រាស លេខ .................... ផ្លូវ ..... .................. សង្កាត់........ ...........ខណ្ឌ....................
ក្រុង ........................ លេខទូរស័ព្ទ.............................. លេខទូរសារ..................................

៧. ចំនួននិយោជិត កម្មករ សរុប ........................នាក់ ស្រី ............... នាក់ ប្រុស .................... នាក់
ក្នុងនោះ :
- មានកម្មករ និយោជិត អាយុពី ១៥ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ចំនួន ...................... នាក់
ស្រី .................. នាក់ ប្រុស .................. នាក់
- មានជនបរទេស ចំនួន ............... នាក់ ស្រី ...................... នាក់ ប្រុស ...................... នាក់

៨. រយៈពេលនិងប្រភេទការងារពេលយប់សម្រាប់ស្ត្រី ឬ ក្មេងប្រុសស្រីមានបដិបញ្ញត្តិ ..............................
..........................................................................................
..........................................................................................
..........................................................................................

៩. មានកម្មករ និយោជិតអាយុក្រោម ១៨ ឆ្នាំ ស្នាក់នៅក្នុងសហគ្រាសចំនួន.......នាក់ (ស្រី........នាក់)

១០. ប្រភេទគ្រឿងចក្រ និងវិធីប្រើសំភារៈ វត្ថុធាតុដើមប្រកបដោយគ្រោះថ្នាក់ ..........................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

១១. ថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ..........................................................................................

ភ្នំពេញ,ថ្ងៃទី...............ខែ..................ឆ្នាំ ....

ហត្ថលេខា ម្ចាស់ ឬ នាយកសហគ្រាស

<u>កំណត់សំគាល់ :</u>

១)៖ សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាក្រុមហ៊ុនអនាមិក

-ឬ ជាក្រុមហ៊ុនទទួលខុសត្រូវមានកំណត់សីមា

-ឬ ជាក្រុមហ៊ុនខែមូលធន

-ឬ ជាសហគ្រាសឯកជន

២)៖ សូមបញ្ជាក់ត្រង់ចំណុចនេះថា :

-ជាសហគ្រាសឧស្សាហកម្ម

-ឬ ជាសហគ្រាសសំណង់

-ឬ ជាសហគ្រាសពាណិជ្ជកម្ម

-ឬ ជាសហគ្រាសសេវាកម្ម

-ឬ ជាសហគ្រាសសិប្បកម្ម

-ឬ ជាសហគ្រាសកសិកម្ម

នៃប្រកាសលេខ ...២៤៨...
ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១...

# សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក

| | | |
|---|---|---|
| យីហោ:............<br>អាសយដ្ឋាន:ផ្ទះលេខ:............ផ្លូវ:............សង្កាត់:............<br>ខ័ណ្ឌ:............ក្រុង:............ទូរស័ព្ទ:............<br>ឈ្មោះម្ចាស់គ្រឹះស្ថាន:............សញ្ជាតិ:............<br>ឈ្មោះនាយកគ្រឹះស្ថាន:............សញ្ជាតិ:............ | ផ្នែកសកម្មភាពសេដ្ឋកិច្ច:............<br>ផលិតផលសំខាន់:............<br>លក្ខន្តិកៈគតិយុត្តនៃសហគ្រាស:............ | ចំនួនបុគ្គលិកសព្វថ្ងៃ:............នាក់<br>ចំនួនបុគ្គលិកមធ្យម: (១) ............នាក់<br>គិតត្រឹមថ្ងៃទី.........ខែ...........ឆ្នាំ |

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | លេខសៀវភៅការងារ | ប្រាក់ប្រចាំខែ | របៀបបើកប្រាក់ | ថ្ងៃខែឆ្នាំចូលធ្វើការ | មុខងារ | កិតប្បធម៌ ឬ កិតវិជ្ជាជីវៈ | ចំនួនម៉ោងធ្វើការក្នុងមួយអាទិត្យ | កំណត់សំគាល់របស់ការិយាល័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| | ក_អ្នកដឹកនាំ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ខ_និយោជិតការិយាល័យ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | គ_កម្មករជំនាញខ្ពស់ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឃ_កម្មករជំនាញ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ង_កម្មករពាក់កណ្តាលជំនាញ | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ច_ហត្ថករឯកទេស | | | | | | | | | | | | |
| | | | | | | | | | | | | | |
| | ឆ_ហត្ថករ | | | | | | | | | | | | |
| | | | | | | | | | | | | | |

កំណត់សំគាល់ : • បើគ្មានពត៌មានដែលត្រូវចុះ
ត្រូវដាក់ក្នុងខ្ទង់ទី១ ជាគ្មាន

ភ្នំពេញ.ថ្ងៃទី............ខែ............ឆ្នាំ............
ហត្ថលេខាម្ចាស់ ឬនាយកសហគ្រាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

ភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០១

លេខ : ៣០០ សកបយ.

# ប្រកាស

## ស្តីពី

## ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ១០៧ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០១ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករប្រចាំឆ្នាំ២០០២។

## សំរេច

ប្រការ១: ថ្ងៃបុណ្យដែលត្រូវឈប់ ហើយបានប្រាក់ឈ្នួលនៅ ឆ្នាំ ២០០២ សំរាប់កម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារត្រូវបានកំណត់ដូចតទៅ:-

- បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០១ ខែមករា
- បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា
- បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា
- បុណ្យចូលឆ្នាំប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៥ ១៦ និងថ្ងៃទី ១៧ ខែ មេសា ជំនួសថ្ងៃទី ១៤ ខែ មេសា ដែលចំថ្ងៃអាទិត្យ

- បុណ្យវិសាខបូជាចំនួនមួយថ្ងៃ ពីថ្ងៃទី ២៦ ខែ មេសា
- ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ ពីថ្ងៃទី ៣០ ខែ មេសា
- បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ ពីថ្ងៃទី ០១ ខែ ឧសភា
- បុណ្យទិវាកុមារអន្តរជាតិចំនួនមួយថ្ងៃ ពីថ្ងៃទី ០១ ខែ មិថុនា
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុចំនួនមួយថ្ងៃពីថ្ងៃទី ១៨ ខែមិថុនា
- បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ចំនួនមួយថ្ងៃ ពីថ្ងៃទី ២៤ ខែ កញ្ញា
- បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ ពីថ្ងៃទី ០៥ ០៧ និងថ្ងៃទី ០៨ ខែតុលា ជំនួសថ្ងៃទី ០៦ ខែ តុលា ដែលចំថ្ងៃអាទិត្យ
- បុណ្យទិវាសិទ្ធិសញ្ញាសន្តិភាពក្រុងប៉ារីសចំនួនមួយថ្ងៃ ពីថ្ងៃទី ២៣ ខែ តុលា
- ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុចំនួនបីថ្ងៃ គឺនៅថ្ងៃទី ៣០ ៣១ ខែ តុលា និងថ្ងៃទី ០១ ខែ វិច្ឆិកា
- បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ ពីថ្ងៃទី ០៩ ខែវិច្ឆិកា
- ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុកចំនួនបីថ្ងៃ គឺនៅថ្ងៃទី ១៨ ១៩ និងថ្ងៃទី ២០ ខែ វិច្ឆិកា
- បុណ្យទិវាសិទ្ធិមនុស្សចំនួនមួយថ្ងៃ ពីថ្ងៃទី ១០ ខែ ធ្នូ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ ពាមពោលការពើដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវអោយឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករ និយោជិតទាំងអស់ ។

**ប្រការ៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"

- អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- សមាគមនិយោជក
- សហព័ន្ធសហជីព

  "ដើម្បីជ្រាប"

- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
- រាជកិច្ច

(ត្រា)

អ៊ិត សំហេង

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធនធានទឹក និង ឧតុនិយម

លេខ 271 ធទឧ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មាធិការចំរុះ
## សំរាប់រៀបចំឯកសារការអភិវឌ្ឍន៍សកម្មភាព និងទស្សនៈទឹកជាតិ
## និងបង្កើនការយល់ដឹងក្នុងការគ្រប់គ្រងធនធានទឹកចំរុះ

&&&&&&&&

## រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញលិខិតលេខ ១០៣១ ធទឧ ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០១ របស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញលិខិតលេខ ១៤៧៧ ឧរថទស.លស ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ២៧១៥ ក.អ.ជ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១ របស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញលិខិតលេខ ១១៦៦ គជទមក ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានឃើញលិខិតលេខ ២៨៧ ប.ស្ថ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ របស់ក្រសួងបរិស្ថាន
- បានឃើញការចាំបាច់របស់ក្រសួងធនធានទឹក និងឧតុនិយម

## ស ំ រេ ច

**ប្រការ ១**

បង្កើតគណៈកម្មាធិការចំរុះមួយ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ុន ហៀន** | អគ្គនាយកកិច្ចការបច្ចេកទេស<br>ក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| ២. លោក **ថេង តារា** | ប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក<br>ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៣. លោក **ពេជ្រ វាសនា** | ប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការ<br>អន្តរជាតិ ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៤. លោក **ជ្រៀន សេងគង់** | អនុប្រធាននាយកដ្ឋានទឹកស្អាត<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៥. លោក **ជ្រឹន សុខា** | ប្រធានការិយាល័យគ្រប់គ្រងគុណភាពទឹក និងដី<br>ក្រសួងបរិស្ថាន | សមាជិក |
| ៦. លោក **អ៊ុក តារា** | នាយការិយាល័យ<br>ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧. លោក **ហ៊ួន ស៊ុនផាន** | អ្នកសំរបសំរួលកម្មវិធីប្រើប្រាស់ទឹក<br>គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |

**ប្រការ ២ :**

គណៈកម្មាធិការចំរុះខាងលើនេះ មានភារកិច្ចរៀបចំ និងចងក្រងឯកសារ ស្តីពី ការអភិវឌ្ឍន៍សកម្មភាព និងទស្សនៈទឹកជាតិ (Develop National Water Vision and Framework for Action) និងបង្កើនការយល់ដឹងក្នុងការគ្រប់គ្រងធនធានទឹកចំរុះ (Raise Awareness of IWRM) ។

**ប្រការ ៣ :**

អគ្គនាយក អគ្គាធិការ ប្រធានគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី 12 ខែ 11 ឆ្នាំ ២០០១

**រដ្ឋមន្ត្រី**

លឹម គានហោ

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម
- គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
- ដូចក្នុងប្រការ ៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ:......០០១......អយក សរ

# សារាចរ

## ស្តីពីគំរូរចនាសម្ព័ន្ធ និង ឈ្មោះសញ្ញាប័ត្រ បច្ចេកទេសនិងវិជ្ជាជីវៈ

●យោងកំណត់ហេតុប្រជុំអន្តរក្រសួង នាថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់រចនាសម្ព័ន្ធ និង ឈ្មោះសញ្ញាប័ត្រ បច្ចេកទេស ឬឯកទេស និង វិជ្ជាជីវៈ ។

●ដើម្បីអោយមានការឯកភាពគ្នាក្នុងការចេញសញ្ញាប័ត្របច្ចេកទេស និង វិជ្ជាជីវៈដែលស្ថិតក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និង កីឡា សូមធ្វើការណែនាំលំអិត ដូចតទៅ ៖

១."សញ្ញាប័ត្របច្ចេកទេសនិង វិជ្ជាជីវៈកំរិតទី១ ឬកំរិតទី២ ឬកំរិតទី៣ "ផ្តល់អោយចំពោះសិស្សរៀន ចប់ថ្នាក់ទី ៩ ហើយបានទទួលការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេល១ ឆ្នាំ ឬ២ ឆ្នាំ ឬ៣ ឆ្នាំ (9+1 +1 +1 ) ។

២." សញ្ញាប័ត្រជាន់ខ្ពស់បច្ចេកទេស ឬ ឯកទេស " ផ្តល់អោយចំពោះនិស្សិតដែល មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើ ហើយបានទទួលការអប់រំបច្ចេកទេស ឬ ឯកទេស រយៈពេល ពីរឆ្នាំយ៉ាងតិច ( Bac +2 ) និង ចំពោះនិស្សិតដែលមានសញ្ញាប័ត្របច្ចេកទេស និង វិជ្ជាជីវៈកំរិតទី៣ហើយបានទទួលការអប់រំបច្ចេកទេសយ៉ាងតិច ២ ឆ្នាំ ( 9 +3+2 ) ។

៣." សញ្ញាប័ត្រសាកលវិទ្យាល័យបច្ចេកទេស ឬឯកទេស" ផ្តល់អោយចំពោះនិស្សិតដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែលមានតំលៃស្មើហើយបានទទួលការអប់រំបច្ចេកទេស ឬឯកទេស តាមប្រព័ន្ធសាកលវិទ្យាល័យ រយៈពេលយ៉ាងតិច ២ ឆ្នាំ ( Bac +2 ) ។

៤."សញ្ញាប័ត្រវិស្វករ ឬ បរិញ្ញាប័ត្រ" ផ្តល់អោយចំពោះនិស្សិតដែលមានសញ្ញាប័ត្រជាន់ខ្ពស់បច្ចេកទេស ឬ ឯកទេស ឬ សញ្ញាប័ត្រ សាកលវិទ្យាល័យបច្ចេកទេស ឬឯកទេស ហើយ បានទទួលការអប់រំបច្ចេកទេស ឬឯកទេស រយៈពេលយ៉ាងតិច ២ឆ្នាំ ( Bac +2 +2 ) និង ចំពោះនិស្សិតដែល មានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាប័ត្រដែល មានតំលៃស្មើ ហើយបានទទួលការអប់រំបច្ចេកទេស ឬឯកទេស យ៉ាងតិច ៤ឆ្នាំ ។

៥." សញ្ញាប័ត្រមធ្យមសិក្សាសិល្បៈបឋមភូមិ " ផ្តល់អោយចំពោះសិស្សរៀនចប់ថ្នាក់ទី ៩ ហើយបានទទួលការអប់រំបណ្តុះបណ្តាលផ្នែកសិល្បៈរយៈពេល យ៉ាងតិច ២ ឆ្នាំ ( 9+2 ) ។

៦ "ស្នាតកប័ត្រសិល្បៈ" ផ្តល់អោយចំពោះសិស្សដែលទទួលបានសញ្ញាប័ត្រមធ្យមសិក្សាសិល្បៈបឋមភូមិហើយបានទទួលការអប់រំបណ្តុះបណ្តាល ផ្នែកសិល្បៈរយៈពេល យ៉ាងតិច ៣ ឆ្នាំ ( 9+2+3 ) ។

៧." វិញ្ញាបនប័ត្រវិជ្ជាជីវៈ" សំរាប់ផ្តល់អោយអ្នកធ្វើការហ្វឹកហាត់ វិជ្ជាជីវៈតិចជាង ១ឆ្នាំ ។

**អំពីទំហំ និង ខ្នាតៈ**

-សញ្ញាប័ត្រវិស្វករឬបរិញ្ញាប័ត្រ ( បណ្តោយ ៤០ស.ម គុណ ទទឹង ៣០ស.ម ) ។

-សញ្ញាប័ត្រជាន់ខ្ពស់បច្ចេកទេសឬសញ្ញាប័ត្រជាន់ខ្ពស់ឯកទេស ( បណ្តោយ៤០ស.ម គុណទទឹង៣០ស.ម) ។

-សញ្ញាប័ត្របច្ចេកទេស និង វិជ្ជាជីវៈ ( បណ្តោយ ៣៥ស.ម គុណ ទទឹង២៥ស.ម ) ។

-វិញ្ញាបនប័ត្រ ( បណ្តោយ ៣០ស.ម គុណ ទទឹង ២០ស.ម ) ។

**អំពីពណ៌** ៖ សពងមាន់

ភ្នំពេញ , ថ្ងៃទី...០៤...ខែ....១១......ឆ្នាំ ២០០១

ជ. រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

រដ្ឋលេខាធិការ

Kiâan Pah

ពុំង ពៅ

ចំលងជូន

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ

" ដើម្បីជូនជ្រាប "

-គ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ " ដើម្បីអនុវត្ត"

-ឯកសារ